**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ភស្តុតាងក្នុងរឿងក្តីរដ្ឋប្បវេណី

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គឹមឡេង**

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **លឹម ស៊ីផេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **លឹម ស៊ីផេង** ជានិស្សិតដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក អ្នកម្តាយ**ដែលជាអ្នកមានគុណបំផុតដែលបានផ្តល់កំណើតដល់រូបខ្ញុំបាទ ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សាកូន អប់រំ ទូន្មានប្រៀនប្រដៅ និងផ្តល់ភាពកក់ក្តៅដល់កូន ឱ្យកូនប្រកបដោយព្រហ្មវិហារធម៌ តាំងពីកូននៅតូចរហូតដល់ធំពេញវ័យ និងបានបញ្ចប់ការសិក្សា។ លោកទាំងពីរបានខិតខំប្រឹងប្រែង ពលីអស់ពីកំលាំងកាយ កំលាំងចិត្តដើម្បីផ្គត់ផ្គង់ទំនុកបម្រុងដល់រូបកូនទាំងផ្នែកស្មារតី ទាំងសម្ភារៈ ថវិកា និងពេលវេលាយកចិត្តទុកដាក់ដល់រូបកូន ដែលជាកត្តាមួយជួយជម្រុញឱ្យការសិក្សារបស់កូនទទួលបានជោគជ័យ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រការផ្នែកនីតិសាស្ត្រ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការរៀបចំកម្មវិធីសិក្សា និងបង្ហាត់បង្រៀន អប់រំដល់រូបខ្ញុំបាទចាប់តាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់ការសិក្សាដោយជោគជ័យ។

សាស្ត្រាចារ្យណែនាំ លោកសាស្ត្រាចារ្យ **ហ៊ីង គីមឡេង** ដែលបានខិតខំអស់ពីកំលាំងកាយ កំលាំងចិត្ត និងចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការដឹកនាំការស្រាវជ្រាវ ដោយបានបង្ហាញនូវគំនិត និងផ្តល់មតិយោបល់ល្អៗដល់ខ្ញុំបាទដែលជាកត្តាជំរុញ ឱ្យសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទអាចបញ្ចប់បានប្រកបដោយជោគជ័យ។

គុណស្រ័យរបស់អ្នកមានគុណទាំងអស់គ្នា ពុំមានអ្វីប្រៀបផ្ទឹមបានឡើយ។ ដើម្បីសម្តែងនូវការដឹងគុណនេះ ខ្ញុំបាទពុំមានអ្វីក្រៅពីសូមធ្វើការបួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងឡាយ ដែលមាននៅក្នុងភពផែនដីនេះ សូមឱ្យជួយមេត្តាឃុំគ្រង និងតាមថែរក្សា ដល់លោកអ្នកមានគុណទាំងអស់គ្នា ឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងសម្រេចបាននូវគ្រប់កិច្ចការទាំងអស់ដោយជោគជ័យ។

# អារម្ភកថា

ក្រោយពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំ។ ដោយនៅឆ្នាំទី៤ នៅក្នុងអំឡុងឆមាសទី២ ខ្ញុំបាទបានចំណាយពេលដើម្បីស្រាវជ្រាវ និងចងក្រងអត្ថបទសារណាដើម្បីបញ្ចប់ការសិក្សា ហើយខ្ញុំបាទបានធ្វើការស្រាវជ្រាវនូវរាល់ឯកសារជាច្រើនដែលមានដូចជា ក្រមងអត្ថបទគតិយុត្ត ឯកសារច្បាប់នានា សៀវភៅដែលបានចងក្រងដោយសាស្ត្រាចារ្យ និងឯកសារមួយចំនួនទៀតដែលជាជំនួយក្នុងការស្រាវជ្រាវសារណាបទមួយនេះឡើង។ ចំពោះការចងក្រងអត្ថបទមួយនេះក៏បានជួបនូវបញ្ហាមួយចំនួនក្នុងការស្រាវជ្រាវ ដោយហេតុថា ឯកសារមួយចំនួនមានភាពពិបាកក្នុងស្វែងរក និងជួបបញ្ហាដទៃផ្សេងទៀតដូចជាខ្វះព័ត៌មានលំអិតពីចំណុចដែលចង់បានជាដើម។ បើទោះបីជាមានភាពលំបាកក្នុងការចងក្រងនៅអត្ថបទមួយនេះយ៉ាងណាក្តី ក៏ខ្ញុំបាទព្យាយាមឱ្យអស់ពីសមត្ថភាពក្នុងការស្រាវជ្រាវ និងស្វែងរកឯកសារនានា ដើម្បីចងក្រង និងរៀបចំអត្ថបទសារណាមួយនេះឱ្យបានបញ្ចប់ជាស្ថាពរ។

ខ្ញុំបាទសរសេរ និងចងក្រងអត្ថបទសារណាដែលស្តីអំពី **ភស្តុតាងក្នុងរឿងរដ្ឋប្បវេណី** នេះក្នុងគោលបំណងដើម្បីទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយ និងសង្ឃឹមថាអាចជួយដល់អ្នកដែលត្រូវការសម្រាប់សិក្សា ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងប្រធានបទនេះ។ មួយវិញទៀតការចងក្រងអត្ថបទសារណាមួយនេះ គឺជាស្នាដៃលើកដំបូងរបស់រូបខ្ញុំបាទដូចនេះតែងតែមានចំណុចខ្វះខាតដែលត្រូវកែតម្រូវ។ ការស្រាវជ្រាវនេះ គឺគ្រាន់តែជាការចូលរួមចំណែកដ៏តូចមួយដល់ការលាតត្រដាងដល់តថភាពខាងផ្លូវច្បាប់ផ្នែកនីតិវិធីដែលកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននេះតែប៉ុណ្ណោះ។ ដូចនេះ ខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថា មិត្តអ្នកអានទាំងអស់គ្នានឹងអធ្យាស្រ័យរាល់ចំនុចខ្វះខាតដែលមាននៅក្នុងអត្ថបទសារណាមួយនេះ។

ជាចុងបញ្ចប់នេះ សូមលោកអ្នកអានមេត្តាអនុគ្រោះរាល់កំហុសទាំងឡាយដែលកើតមានឡើងនៅក្នុងអត្ថបទសារណាមួយនេះ។ មួយវិញទៀតខ្ញុំបាទ ក៏សូមទទួលយកការរិះគន់ដើម្បីស្ថាបណាក្នុងការអភិវឌ្ឍសមត្ថភាព ដោយក្តីគោរព និងក្តីរាប់អានយ៉ាងកក់ក្តៅបំផុត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១
## សញ្ញាណគតិយុត្ត និងប្រភេទនៃភស្តុតាង

**ផ្នែកទី១ សញ្ញាណនៃភស្តុតាង** ............ ៣
១.១.អត្ថន័យនៃភស្តុតាង ............ ៣
១.២.គោលការណ៍នៃការសម្រេចសេចក្តីដោយភស្តុតាង ............ ៤

**ផ្នែកទី២ ប្រភេទនៃភស្តុតាង** ............ ៥
២.១.ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល ............ ៥
២.២.ភស្តុតាងជាមនុស្ស និងភស្តុតាងជាវត្ថុ ............ ៧
២.៣.ភស្តុតាងស្រប និងភស្តុតាងផ្ទុយ ............ ៨

## ជំពូកទី២
## ការបញ្ជាក់នៃភស្តុតាង និងការទទួលខុសត្រូវក្នុងការបញ្ជាក់

**ផ្នែកទី១ ការព្សាក់នៃភស្តុតាង** ............ ១០
១.១.កម្មវត្ថុក្នុងការបញ្ជាក់ភស្តុតាង ............ ១០
ក.អង្គហេតុ ............ ១០
ខ.វិធានតាមបទពិសោធ ............ ១១
គ.បញ្ញត្តិច្បាប់ ............ ១១
១.២.អង្គហេតុដែលមិនបញ្ជាក់ភស្តុតាង ............ ១២
ក.ការសារភាពតាមផ្លូវតុលាការ ............ ១២
ខ.ការចាត់ទុកថាបានសារភាព ............ ១៤
គ.អង្គហេតុជាក់ស្តែង ............ ១៥
១.៣.គោលការណ៍នៃជំនឿទុកចិត្តដោយសេរី និងការវាយតម្លៃ ............ ១៥
ក.អត្ថន័យនៃគោលការណ៍ជំនឿទុកចិត្តដោយសេរី ............ ១៥
ខ.ការវាយតម្លៃដោយសេរី ............ ១៦
គ.ការកម្រិតចំពោះគោលការណ៍ជំនឿទុកចិត្តដោយសេរី ............ ១៧

**ផ្នែកទី២ ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង** ................................. ១៧
២.១.ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ........................................ ១៨
២.២.ការសន្មតតាមច្បាប់ ........................................................................ ១៩

## ជំពូកទី៣
## នីតិវិធីនៃការពិនិត្យភស្តុតាង និងការថែរក្សាការពារភស្តុតាង

**ផ្នែកទី១ នីតិវិធីនៃការពិនិត្យភស្តុតាង** ........................................................ ២១
១.១.ការពិនិត្យភស្តុតាង ........................................................................ ២១
១.២.ការពិនិត្យភស្តុតាងដោយសម្ងាត់វិធី ........................................................ ២២
១.២.១.សាក្សី ........................................................................ ២២
ក.ការសាកសួរសាក្សី ........................................................................ ២២
ខ.សម្បថ ........................................................................ ២៣
គ.វិធីនៃការសាកសួរសាក្សី ........................................................................ ២៤
ឃ.ការកម្រិតទៅលើសំណួរ ........................................................................ ២៥
១.២.២.ភាគី ........................................................................ ២៦
ក.ការសាកសួរភាគី ........................................................................ ២៦
ខ.ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់ ........................ ២៧
១.២.៣.កោសលវិច័យ ........................................................................ ២៧
១.២.៤.ភស្តុតាងជាឯកសារ ........................................................................ ២៨
ក.ឯកសារសាធារណៈ ........................................................................ ២៩
ខ.ឯកសារឯកជន ........................................................................ ៣០
គ.ការផ្តល់ឯកសារ ........................................................................ ៣០
១.២.៥.ការត្រួតពិនិត្យ ........................................................................ ៣១

**ផ្នែកទី២ ការថែរក្សាការពារភស្តុតាង** ........................................................ ៣២
២.១.នីតិវិធីថែរក្សាការពារភស្តុតាង ........................................................ ៣២
២.២.លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារ ..................... ៣៣

**សេចក្តីសន្និដ្ឋាន** ........................................................................ ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅក្នុងប្រទេសកម្ពុជាក្រោយពីមានការវិវត្តជាច្រើនសម័យកាលមក យើងសង្កេតឃើញថាប្រទេសមួយនេះមានការអភិវឌ្ឍជាបន្តបន្ទាប់ ហើយចំពោះការអនុវត្តច្បាប់ទៀតសោតក៏ត្រូវបានធ្វើវិសោធនកម្មជាច្រើនលើកច្រើនសារមកហើយដែរ ដើម្បីធានាថាច្បាប់ដែលត្រូវអនុវត្តនោះមានភាពស៊ីសង្វាក់គ្នាទៅតាមសម័យកាលនីមួយៗ។ ដោយឡែកយើងសង្កេតឃើញថាមានច្បាប់មួយចំនួនដែលបានបង្កើតឡើងក្នុងគោលបំណងដើម្បីប្រាស្រ័យទាក់ទងគ្នារវាងបុគ្គលឯកជន និងបុគ្គលឯកជន ដោយមិនមានជ្រៀតជ្រែកពីសំណាក់រដ្ឋឡើយ ដែលច្បាប់នោះហៅថា នីតិរដ្ឋប្បវេណី ដែលគ្របដណ្តប់លើវិស័យឯកជន។ ទោះបីជាមាននីតិរដ្ឋប្បវេណី ដើម្បីគ្រប់គ្រងទំនាក់ទំនងរបស់បុគ្គលឯកជនក្តី ក៏វាមិនទាន់មានភាពគ្រប់គ្រាន់ដែរ ដោយហេតុថា នីតិរដ្ឋប្បវេណីជាច្បាប់សារធាតុដែលបានចែងអំពីវិធានទូទៅក្នុងការអនុវត្តប៉ុណ្ណោះ។ ដូចនេះហើយទើបមានការបង្កើតឡើងនូវច្បាប់នីតិវិធីរដ្ឋប្បវេណីដែលជាវិធាននៃការកំណត់អំពីនីតិវិធីទៅតុលាការ នៅពេលដែលគូភាគីមានវិវាទកើតឡើង។ នៅពេលមានវិវាទកើតឡើងគេត្រូវអនុវត្តតាមច្បាប់នីតិវិធីដែលបានកំណត់អំពីនីតិវិធីនៅក្នុងរឿងក្តីទៅតាមដំណាក់កាលនីមួយៗ ដែលស្ថាប័នតុលាការជាអ្នកអនុវត្តច្បាប់នីតិវិធីនេះ។

ហេតុនេះ នៅពេលដែលមានវិវាទកើតមានឡើងភាគីត្រូវធ្វើពាក្យបណ្តឹងទៅតុលាការដើម្បីឱ្យតុលាការស្វែងរកយុត្តិធម៌ឱ្យខ្លួន ទន្ទឹមនឹងនេះភាគីដែលមានវិវាទនោះត្រូវប្រាប់អំពីមូលហេតុនៃបណ្តឹងនឹងធ្វើការបញ្ជាក់អំពីអង្គហេតុទៅតុលាការតាមរយៈពាក្យបណ្តឹងដែលខ្លួនបានធ្វើនោះ។ ហើយនៅក្នុងពាក្យបណ្តឹងភាគីត្រូវសរសេរឱ្យបានច្បាស់ឱ្យស្របទៅតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា លើសពីនេះប្រសិនបើមានភស្តុតាងដើម្បីបញ្ជាក់អំពីអត្ថិភាពនៃអង្គហេតុនោះភាគីត្រូវតែដាក់ជូនតុលាការដើម្បីធ្វើការពិនិត្យ។ វត្តមានភស្តុតាងពិតជាមានសារៈសំខាន់ណាស់ ក្នុងការបញ្ជាក់អំពីអង្គហេតុណាមួយថាពិត ឬមិនពិត។ ភស្តុតាងមាននៅក្នុងរឿងក្តីព្រហ្មទណ្ឌផង និងរឿងក្តីរដ្ឋប្បវេណីផង ប៉ុន្តែនៅក្នុងអត្ថបទសារណាមួយនេះនឹងធ្វើការសិក្សាស៊ីជម្រៅទៅលើភស្តុតាងនៅក្នុងរឿងក្តីរដ្ឋប្បវេណី ថាតើភស្តុតាងជាអ្វី? តើភស្តុតាងត្រូវបានតុលាការធ្វើការពិនិត្យនៅពេលណា? ដើម្បីឱ្យភាគីនៃវិវាទទទួលបានយុត្តិធម៌តើតុលាការនឹងធ្វើការសម្រេចសេចក្តីលើភស្តុតាងយ៉ាងដូចម្តេច?

ការសិក្សាស៊ីជម្រៅទៅលើប្រធានបទ **"ភស្តុតាងនៅក្នុងរឿងក្តីរដ្ឋប្បវេណី"** ដើម្បីឱ្យយើងបានយល់អំពីការសម្រេចសេចក្តីរបស់ចៅក្រម ដោយចៅក្រមពុំមែនធ្វើការសម្រេចសេចក្តីតាមទំនើងចិត្តដែលខ្លួននឹកឃើញនោះទេ។ ការសម្រេចសេចក្តីទៅលើអង្គហេតុនីមួយៗ ចៅក្រមធ្វើការសម្រេចសេចក្តីដោយផ្អែកលើភស្តុតាងដែលគូភាគីបានផ្តល់ឱ្យខ្លួន ឬភស្តុតាងដែលតុលាការធ្វើការស្វែងរកតាមរយៈការស្រាវជ្រាវ និងការពិនិត្យយ៉ាងលម្អិត ដើម្បីអាចបញ្ជាក់អំពីភាពត្រឹមត្រូវនឹងយុត្តិធម៌ក្នុង

ការជំនុំជម្រះក្តីរបស់តុលាការ។ លើសពីនេះ យើងក៏អាចដឹងថាភស្តុតាងប្រភេទណាខ្លះដែលយកមកប្រើប្រាស់បានក្នុងរឿងក្តីរដ្ឋប្បវេណី ហើយក៏បានយល់អំពីតួនាទីរបស់គូភាគីក្នុងការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងដែលខ្លួនបានដាក់ជូនតុលាការផងដែរ។

ហេតុនេះ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សាស៊ីជម្រៅទៅលើអត្ថបទសារណានេះ គប្បីធ្វើការបែងចែកប្រធានបទនេះជា៣ជំពូក ដូចជា៖

**ជំពូកទី១ សញ្ញាណគតិយុត្ត និងប្រភេទនៃភស្តុតាង**
**ជំពូកទី២ ការបញ្ជាក់នៃភស្តុតាង និងការទទួលខុសត្រូវក្នុងការបញ្ជាក់**
**ជំពូកទី៣ នីតិវិធីនៃការពិនិត្យភស្តុតាង និងការថែរក្សាការពារភស្តុតាង។**

**ꕥꕥ✶ꕤꕤ**

# ជំពូកទី១
# សញ្ញាណគតិយុត្ត និងប្រភេទនៃតស៊ូតាង

# ជំពូកទី១
# សញ្ញាណគតិយុត្ត និងប្រភេទនៃភស្តុតាង

## ផ្នែកទី១ សញ្ញាណនៃភស្តុតាង

ដើម្បីឱ្យចៅក្រមអាចធ្វើការវិនិច្ឆ័យអំពីវិវាទនៃអង្គហេតុណាមួយដែលគូភាគីនៃវិវាទបានធ្វើការទាមទារ លុះត្រាតែមានភស្តុតាងច្បាស់លាស់ក្នុងការបញ្ជាក់ និងមានសំអាងហេតុ ព្រមទាំងសំអាងច្បាប់ត្រឹមត្រូវដើម្បីឱ្យការទាមទាររបស់ភាគីមានប្រសិទ្ធិភាព។ អាស្រ័យហេតុនេះយើងត្រូវតែយល់ឱ្យបានច្បាស់អំពីអត្ថន័យនៃភស្តុតាង យើងនឹងធ្វើការបង្ហាញអំពីនិយមន័យនៃភស្តុតាង និងគោលការណ៍នៃការសម្រេចសេចក្តីដោយភស្តុតាង។

### ១.១. អត្ថន័យនៃភស្តុតាង

ភស្តុតាង គឺជាតឹកតាង ជាគ្រឿងសម្គាល់ ជាសំអាង[1]។

ភស្តុតាង គឺជាមធ្យោបាយសម្រាប់ដាក់ទៅឱ្យតុលាការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុណាមួយថាមានការពិត ឬគ្មានការពិត ដែលជាមូលដ្ឋានសម្រាប់ឱ្យតុលាការធ្វើការពិចារណាទៅលើអង្គហេតុ ព្រមទាំងចេញសាលក្រមដោយផ្អែកលើគោលការណ៍ជំនឿទុកចិត្តដោយសេរីរបស់ចៅក្រម។ លើសពីនេះ ភស្តុតាងនៅក្នុងរឿងក្តីរដ្ឋប្បវេណីអាចដាក់បានមុននីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយភាគីមានកាតព្វកិច្ចជាអ្នករៀបចំភស្តុតាងដើម្បីដាក់ជូនតុលាការ។ ហើយភស្តុតាងក៏អាចជាប្រព្រឹត្តហេតុ ឬអង្គហេតុទាំងឡាយណាដែលទម្រង់នីតិវិធីនៃការបង្ហាញអង្គហេតុទាំងនោះត្រូវបានកំណត់ដោយច្បាប់។ លើសពីនេះភស្តុតាងក៏ជាអ្វីៗដែលមានពិតដោយផ្អែកទៅតាមបញ្ញត្តិច្បាប់ តុលាការអាចសន្មតថាមាន ឬក៏គ្មាននូវរាល់ស្ថានភាពលំអិតផ្សេងៗទៀតដែលមានអត្ថន័យក្នុងការដោះស្រាយអោយបានត្រឹមត្រូវនៃរឿងក្តីរដ្ឋប្បវេណី។ ពេលខ្លះទៀតភស្តុតាងក៏ត្រូវបានប្រើប្រាស់ក្នុងន័យថាជា "ឧបករណ៍ភស្តុតាង" ដែលមានន័យថាជាកម្មវត្ថុដែលចៅក្រមត្រូវធ្វើការពិនិត្យ ដែលឧបករណ៍ភស្តុតាងទាំងនោះមានដូចជា សាក្សី អ្នកជំនាញខាងកោសលវិច័យ ភាគីនៃបណ្តឹង (ភស្តុតាងជាមនុស្ស) ឯកសារភស្តុតាង និងវត្ថុដែលត្រូវត្រួតពិនិត្យ (ភស្តុតាងជាវត្ថុ) ជាអាទ៍។ លើសពីនេះ ទៅទៀតអ្វីដែលចៅក្រមបានទទួលដឹងលឺ តាមរយៈការពិនិត្យឧបករណ៍ភស្តុតាងហៅថា "ធនធានភស្តុតាង" ដែលមានដូចជាសេចក្តីថ្លែងការណ៍របស់សាក្សី(ចម្លើយជាកសិណសាក្សី) ឬភាគីនៃបណ្តឹង យោបល់របស់អ្នកជំនាញខាងកោសលវិច័យ ចំណុចដែលមានសរសេរនៅក្នុង

[1] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ទំព័រ៧៤០

ឯកសារណាមួយ ដែលជាលទ្ធផលនៃការត្រួតពិនិត្យជាដើម[2]។

ភស្តុតាង គឺជាព្រឹត្តហេតុ ឬអង្គហេតុទាំងឡាយ (Facts) ដែលអង្គហេតុទាំងនោះបានត្រូវកំណត់ដោយច្បាប់ទៅលើទម្រង់នីតិវិធីនានារបស់វា ដើម្បីធ្វើការបង្ហាញ ឬបដិសេធន៍ទៅលើព្រឹត្តិការណ៍ ( Event ) នៃបទល្មើសណាមួយបាន ដោយអង្គហេតុទាំងនោះបង្ហាញនូវការដាក់បន្ទុក "ឃោរឃៅ" ឬដោះបន្ទុក "ដោះសារ" ចំពោះការទទួលខុសត្រូវរបស់បុគ្គល ព្រមទាំងកំណត់បាននូវកម្រិតខ្ពស់ ឬទាប និងធ្ងន់ ឬស្រាលទៅលើការទទួលខុសត្រូវរបស់បុគ្គលទាំងនោះទៀតផង[3] ។

## ១.២. គោលការណ៍នៃការសម្រេចសេចក្ដីដោយភស្តុតាង

គោលការណ៍នៃការសម្រេចសេចក្ដីដោយភស្តុតាង គឺជាគោលការណ៍តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើភស្តុតាងជាមូលដ្ឋានក្នុងសម្រេចសេចក្ដី[4]។ បើទោះបីជា ការសម្រេចសេចក្ដីរបស់តុលាការពិតជាចាំបាច់មានភស្តុតាងមកធ្វើការបញ្ជាក់ក៏ពិតមែន ប៉ុន្តែក៏មានករណីខ្លះដែលចៅក្រមធ្វើការទទួលស្គាល់អង្គហេតុ ដោយមិនចាំបាច់ធ្វើការពិចារណាអំពីភស្តុតាងទេ ចៅក្រមក៏អាចធ្វើការពិចារណាអំពីស្ថានភាពទាំងមូល ដែលបានលេចឡើងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន(ខ្លឹមសារទាំងមូលនៃការទាញហេតុផល)។

**ឧទាហរណ៍១៖** អំពីស្ថានភាពទាំងមូលមានដូចជាបញ្ហាថាតើសេចក្ដីថ្លែងការណ៍ និងការអះអាងរបស់ភាគី ឬអ្នកតំណាងរបស់ភាគី មានភាពស៊ីសង្វាក់គ្នាដែរឬទេ នៅក្នុងករណីនេះតុលាការអាចធ្វើការសម្រេចសេចក្ដីបានដោយពុំចាំបាច់ផ្អែកលើភស្តុតាងបាន។

**ឧទាហរណ៍២៖** ភាគីមានវិវាទទៅលើវត្តមាននៃរឿងពិត តែវិវាទនោះពុំមានភាពធ្ងន់ធ្ងរពេកទេ ក្នុងករណីនេះ តុលាការអាចទទួលស្គាល់រឿងពិតបានដោយមិនចាំបាច់យោលទៅលើភស្តុតាងទេ[5]។ ហើយករណីលើកលែងមួយទៀតនោះ គឺតុលាការអាចទទួលស្គាល់ទៅលើអង្គហេតុដែលភាគីបានធ្វើការសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្ដែងហើយនោះដោយពុំចាំបាច់ផ្អែកលើភស្តុតាងនោះទេ។ នៅពេលដែលបានសារភាពរួចហើយ តុលាការនឹងវិនិច្ឆ័យសេចក្ដីដោយយោងទៅតាមការសារភាពនោះ ចំណែកឯភាគីម្ខាងទៀតធ្វើការតទល់ និងការពារខ្លួនដោយជឿលើសេចក្ដីសារភាពនោះ ដូច្នេះគេមិនអាចទទួលស្គាល់ឱ្យភាគីដែលបានធ្វើការសារភាពនោះ ធ្វើការដកសេចក្ដីសារភាពរបស់ខ្លួន ដោយគ្មានលក្ខខណ្ឌបានឡើយ។ ប៉ុន្តែនៅក្នុង

[2] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគី១

[3] សៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា

[4] មាត្រា១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[5] សេចក្ដីកំណត់ក្រមនីតិវិធីរដ្ឋប្បវេណី

ករណីដែលភាគីម្ខាងទៀតមិនប្តឹងតវ៉ាជាពិសេសទេ គេអាចទទួលស្គាល់ការដកសេចក្តីសារភាពនោះបាន។ លើសពីនេះ នីតិវិធីត្រៀមសម្រាប់ទាញហេតុផលក៏អាចត្រូវបានចាត់ទុកជាផ្នែកមួយនៃស្ថានភាពដែលបានលេចឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដែរ ព្រោះនីតិវិធីត្រៀមសម្រាប់ទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ដែរ។

## ផ្នែកទី២ ប្រភេទនៃភស្តុតាង

ភស្តុតាងត្រូវបានគេបែងចែកចេញជាបីប្រភេទដែលមានលក្ខណៈខុសៗគ្នា។ ដោយភស្តុតាងទាំងបីប្រភេទនេះមានដូចជា ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល ភស្តុតាងជាមនុស្ស និងភស្តុតាងជាវត្ថុ ភស្តុតាងស្រប និងភស្តុតាងផ្ទុយ[6]។

### ២.១. ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល

ដោយផ្អែកលើមូលដ្ឋាននៃការកំណត់កម្មវត្ថុក្នុងការបញ្ជាក់ដោយភស្តុតាង គេបានបែងចែកភស្តុតាងជាពីរប្រភេទគឺ ភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល។ ភស្តុតាងផ្ទាល់ គឺជាភស្តុតាងដែលបានបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលជាមូលហេតុនៃការទាមទារ ឬហៅថាអង្គហេតុចម្បង។ ភស្តុតាងប្រយោល គឺជាភស្តុតាងដែលគាំទ្រដល់អង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូល ឬហៅថា អង្គហេតុប្រយោល និងអង្គហេតុបន្ទាប់បន្សំ ដែលវាមានប្រយោជន៍ដល់ការបញ្ជាក់ពីអង្គហេតុចម្បង។

**អង្គហេតុចម្បង** គឺជាអង្គហេតុដែលភាគីអះអាងដើម្បីឱ្យតុលាការទទួលស្គាល់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តតាមច្បាប់សារធាតុ ។ ប្រភេទនៃអង្គហេតុចម្បងមានដូចជា៖

- អង្គហេតុដែលនាំឱ្យកកើតឡើងនូវសិទ្ធិ
- អង្គហេតុដែលនាំឱ្យរលត់សិទ្ធិ
- អង្គហេតុទប់ស្កាត់ការប្រើប្រាស់សិទ្ធិ
- អង្គហេតុរារាំងការកកើតឡើងនៃសិទ្ធិ

អង្គហេតុចមម្បងមានតួនាទីសំខាន់ សម្រាប់ឱ្យតុលាការកំណត់ចំណុចវិវាទ និងបន្ទុកនៅក្នុងការបញ្ជាក់ភស្តុតាង។

**ឧទាហរណ៍១៖** A បានធ្វើបណ្តឹងទៅតុលាការរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖

[6] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១

- **ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**[7]៖ ទាមទារឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយ B សងប្រាក់ដើមចំនួន ១.០០០.០០០ (មួយលាន)រៀល និងការប្រាក់១៨% ក្នុងមួយឆ្នាំ ព្រមទាំងការប្រាក់យឺតយ៉ាវ ២៧%ក្នុងមួយឆ្នាំ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

- **អង្គហេតុដែលជាមូលហេតុនៃការទាមទារ**[8]៖

(ក) កាលពីថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៤ A និង B បានចុះកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុដូចដែលដើមចោទបានធ្វើការទាមទារ, ហើយកំណត់សងនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ដូចមាននៅក្នុង**ភស្តុតាងជាកិច្ចសន្យា** (X1)។

(ខ) នៅថ្ងៃដែលបានចុះកិច្ចសន្យាដដែលនេះ A បានប្រគល់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន)រៀល ឱ្យទៅ B ដូចមាននៅក្នុង**ភស្តុតាងជាលិខិតប្រគល់ទទួលប្រាក់** (X2)។

(គ) ដល់ថ្ងៃកំណត់សង B មិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា A បានធ្វើលិខិតដាស់តឿនឱ្យ B អនុវត្តកាតព្វកិច្ច ដូចមាននៅក្នុង**ភស្តុតាងជាលិខិតដាស់តឿនដែលមានហត្ថលេខាទទួលដោយចុងចម្លើយ B** (X3)។

នៅក្នុងឧទាហរណ៍ទី១ខាងលើនេះ ភស្តុតាង (X1), (X2) និង(X3) គាំទ្រអោយអង្គហេតុចម្បង (ក), (ខ) និង(គ) ដែលជាការអះអាងអំពីការកកើតឡើងនៃសិទ្ធិតាមផ្លូវច្បាប់សារធាតុ (សិទ្ធិទាមទារឱ្យសងប្រាក់ផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ ដោយយោងតាមមាត្រា៥៩១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា)។

ហេតុនេះ ភស្តុតាងដែលគាំទ្រដោយផ្ទាល់នូវអង្គហេតុផ្ទាល់ គឺជា**ភស្តុតាងផ្ទាល់**។ ប៉ុន្តែក្នុងករណីមួយចំនួនភស្តុតាងដែលគាំទ្រអោយអង្គហេតុចម្បងពុំអាចរកបានដោយងាយនោះទេ។ ហេតុនេះ ភាគីដែលមានផលប្រយោជន៍ក្នុងបណ្តឹង អាចអះអាងអំពីអង្គហេតុសំខាន់ៗដែលគាំទ្រអោយអង្គហេតុជាមូលហេតុនៃការទាមទារបានដែលគេហៅថា **អង្គហេតុប្រយោល**។

**ឧទាហរណ៍ទី២ ៖** A បានធ្វើបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារដូចខាងក្រោម៖

- **ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ ៖** ទាមទារឱ្យតុលាការបង្គាប់អោយចុងចម្លើយB សងប្រាក់ដើមចំនួន ១.០០០.០០០ (មួយលាន)រៀល និងការប្រាក់ ១៨% ក្នុងមួយឆ្នាំព្រមទាំងការប្រាក់យឺតយ៉ាវ២៧% ក្នុងមួយឆ្នាំ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

---

[7] មាត្រា៧៥ កថាខណ្ឌ២ ចំនុចខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[8] មាត្រា៧៥ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- **អង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖**

**(ក)** កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ A និង B បានចុះកិច្ចសន្យាខ្ចីបរិភោគដែលមានតម្លៃកម្មវត្ថុ ដូចខ្លឹមសារដែលដើមចោទទាមទារ, កំណត់សងថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៥ ដូចមាននៅក្នុង**ភស្តុតាងជាកិច្ចសន្យា(X)**។

**(ខ)** នៅក្នុងថ្ងៃដដែលនេះ A បានប្រគល់លុយឱ្យ B, ដោយ A បានដកលុយពីធនាគារចំនួន ១.០០០.០០០ (មួយលាន)រៀល។

**(គ)** នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ A បានធ្វើការដាស់តឿនទៅ B ដោយផ្ទាល់មាត់ នៅនឹងផ្ទះរបស់ B ។

នៅក្នុងឧទាហរណ៍ទី២ខាងលើនេះ ដើមចោទ A ពុំមានភស្តុតាងផ្ទាល់ណាមួយមកបញ្ជាក់អំពី អង្គហេតុ **(ខ) និង (គ)** បានឡើយ។ ដូចនេះ វត្តមានរបស់អង្គហេតុប្រយោលអាចជួយឱ្យដើមចោទអះអាងអំពីអត្ថិភាពនៃអង្គហេតុចម្បងបាន។ ទោះបីជាពុំមានភស្តុតាងផ្ទាល់ក៏ដោយ ក៏ដើមចោទអាចដាក់ភស្តុតាងប្រយោល ដើម្បីបញ្ជាក់អំពីអង្គហេតុប្រយោលនេះបាន។ ហើយអង្គហេតុប្រយោលនេះអាចនឹងក្លាយជាមូលដ្ឋានសម្រាប់តុលាការពិចារណា ដើម្បីទទួលស្គាល់អង្គហេតុផ្ទាល់។ នៅក្នុងករណីនេះដើមចោទអាចលើកភស្តុតាងប្រយោលដើម្បីធ្វើការបញ្ជាក់អង្គហេតុប្រយោលបាន ដូចជា៖

- របាយការណ៍របស់ធនាគារស្តីពីការដកប្រាក់នៅថ្ងៃដែលដើមចោទអះអាងថាបានប្រគល់ប្រាក់កម្ចីអោយទៅចុងចម្លើយ។
- កាមេរាសុវត្ថិភាពដែលចាប់បាននៅពេលដែលដើមចោទ បានទៅផ្ទះរបស់ចុងចម្លើយដើម្បីធ្វើការដាស់តឿនចុងចម្លើយអោយសងប្រាក់ជាអាទិ៍។

ដូចនេះ របាយការណ៍របស់ធនាគារ និងកាមេរាសុវត្ថិភាព គឺជាភស្តុតាងប្រយោលដែលអាចអោយភាគីដើមចោទទាមទារ។

ដោយសារតែភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោលជាទម្រង់នៃភស្តុតាងដែលកើតចេញពីអង្គហេតុគ្រឹះ ទើបធ្វើឱ្យខ្លឹមសាររបស់វាមានសម្ព័ន្ធភាពមិនអាចកាត់ផ្តាច់បានពីប្រភពនានានៃអង្គហេតុគ្រឹះនោះបានទេ។

### ២.២.ភស្តុតាងជាមនុស្ស និងភស្តុតាងជាវត្ថុ

ក្រៅពីភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល ក៏នៅមានភស្តុតាងអាចជាមនុស្ស និងអាចជាវត្ថុ ហើយវាត្រូវបានហៅថា វិធីភស្តុតាង ឬឧបករណ៍ភស្តុតាង។ ភស្តុតាងជាមនុស្សមានដូចជា សាក្សី សាមីភាគី អ្នកកោសលវិច័យ ។ ហើយភស្តុតាងជាវត្ថុមានដូចជា ភស្តុតាងជាឯកសារ និងវត្ថុដែល

ជាកម្មវត្ថុក្នុងការត្រួតពិនិត្យ។ ភស្តុតាងជាវត្ថុ គឺជាវត្ថុទាំងឡាយណាដែលកើតឡើងមានលក្ខណៈសមស្របទៅតាមការកំណត់របស់នីតិវិធី ហើយដែលវត្ថុទាំងនោះស្ថិតនៅក្នុងលក្ខខណ្ឌទាំងឡាយដែលបម្រើបានជាភស្តុតាងទៅតាមរឿងក្តីនីមួយៗ មានន័យថា វត្ថុដែលជាភស្តុតាងនោះជាប្រភពនៃការផ្តល់ព័ត៌មានអំពីសក្ខីកម្ម ឬអង្គហេតុគ្រឹះ ហើយជាងនេះទៅទៀត វត្ថុខ្លួនឯងនេះក៏អាចកំណត់បាននូវអត្ថិភាពសម្រាប់រឿងអង្គសេចក្តីបានផងដែរ ពោលគឺ **វត្ថុនេះជាប្រភពផ្តល់ព័ត៌មានអំពីអង្គហេតុផង និងវត្ថុខ្លួនឯងនោះបម្រើដល់អត្ថិភាពនៃអង្គសេចក្តីផង**[9]។ ភស្តុតាងជាវត្ថុអាចមានដូចជា ឯកសារ ឬលិខិតនានា (លិខិតឯកជន និងលិខិតសាធារណៈ) របាយការណ៍របស់អ្នកជំនាញកោសលវិច័យ ជាដើម។ លើសពីនេះ ភស្តុតាងជាវត្ថុត្រូវបានគេសង្កេតឃើញនូវលក្ខណៈពិសេសរបស់វា គឺភស្តុតាងជាវត្ថុមានលក្ខណៈដែលមិនអាចជំនួសបានដោយវត្ថុដទៃ គឺមានន័យថា មិនអាចយកវត្ថុណាមួយទៅជំនួសវត្ថុដែលជាភស្តុតាងនេះបានទេ។ ហើយប្រសិនបើភស្តុតាងនោះត្រូវបានបំផ្លាញ នោះមិនត្រូវបានបង្កើតវត្ថុថ្មីសម្រាប់ ធ្វើជាភស្តុតាងយកមកជំនួសវត្ថុនោះបានឡើយ បើទោះបីជាវត្ថុដែលត្រូវជំនួសបាននេះមានលក្ខណៈរូប និងមានសារធាតុផ្សំដូចគ្នាក៏ដោយ[10]។

### ២.៣. ភស្តុតាងស្រប និងភស្តុតាងផ្ទុយ

ភស្តុតាងស្រប គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវបានដាក់ដោយភាគីដើម្បីបញ្ជាក់អំពីអង្គហេតុផ្ទាល់ដែលខ្លួនមានបន្ទុកទទួលខុសត្រូវក្នុងការបញ្ជាក់ផ្ទាល់ខ្លួន។ ចំណែកឯភស្តុតាងផ្ទុយ គឺជាឧបករណ៍ភស្តុតាង (វិធីភស្តុតាង) ដែលត្រូវដាក់ដោយភាគីម្ខាងទៀត ដែលធ្វើការតវ៉ាចំពោះអង្គហេតុដែលត្រូវបានអះអាងនោះ មានន័យថា ភាគីបានធ្វើសេចក្តីថ្លែងការណ៍ដើម្បីបដិសេធនូវអង្គហេតុ ឬមិនបានដឹងអំពីអង្គហេតុនោះ (យោងតាមមាត្រា ៩៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

គោលបំណងនៃភស្តុតាងស្រប គឺធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់។ ផ្ទុយទៅវិញ ភស្តុតាងផ្ទុយ មានគោលបំណងរារាំងចៅក្រមមិនឱ្យមានការជឿជាក់លើភស្តុតាងស្រប ឬផ្លាស់ប្តូរការជឿជាក់ដែលចៅក្រមមានរួចហើយ។ ភស្តុតាងស្រប អាចសម្រេចគោលបំណងរបស់វាបាន តែក្នុងករណីដែលបានធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើអត្ថិភាពនៃអង្គហេតុផ្ទាល់ណាមួយ តែប៉ុណ្ណោះ។ ដោយឡែក ភស្តុតាងផ្ទុយអាចសម្រេចគោលបំណងរបស់វា ដោយគ្រាន់តែធ្វើ

[9] សៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូជា
[10] សៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូជា

ឱ្យការជឿជាក់របស់ចៅក្រមទៅលើអត្ថិភាពនៃអង្គហេតុនៅពេលនោះ មានភាពមិនច្បាស់លាស់តែប៉ុណ្ណោះ ពោលគឺមិនចាំបាច់ធ្វើឱ្យចៅក្រមមានការជឿជាក់ទៅលើនត្ថិភាពនៃអង្គហេតុទេ[11]។

ឈឈ✶ឆឆ

[11] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១

# ជំពូកទី២
# ការបញ្ជាក់នៃភស្តុតាង
# និង
# ការទទួលខុសត្រូវក្នុងការបញ្ជាក់

# ជំពូកទី២
# ការបញ្ជាក់នៃភស្តុតាង និងការទទួលខុសត្រូវក្នុងការបញ្ជាក់

## ផ្នែកទី១ ការបញ្ជាក់នៃភស្តុតាង

តុលាការមិនអាចយកអង្គហេតុណាមួយដែលភាគី មិនបានធ្វើការអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ[12]។ ហេតុនេះទើបត្រូវឱ្យភាគីធ្វើការអះអាងនូវអង្គហេតុណាមួយឱ្យបានច្បាស់លាស់ដោយបង្ហាញនូវភស្តុតាងដែលខ្លួនបានដាក់ជូនតុលាការ ហើយត្រូវចង្អុលបង្ហាញនូវអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងនោះ ការចង្អុលបង្ហាញនេះពុំមានអនុភាពចងតុលាការក្នុងការទទួលស្គាល់អង្គហេតុដែលជាកម្មវត្ថុក្នុងបញ្ជាក់ដោយភស្តុតាងទេ ពោលគឺតុលារអាចធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ភស្តុតាងដែលភាគីបានបញ្ជាក់នោះ ដោយសេរីភាពលើការវាយតម្លៃរបស់តុលាការ។ ហើយតុលាការត្រូវពិចារណាថាតើភស្តុតាងដែលភាគីបានដាក់នោះទៀតសោត មានការគាំទ្រអោយអង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ភាគី ឬអង្គហេតុសំខាន់ៗផ្សេងទៀតដែលចាំបាច់ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាងដែរឬទេ។ ដើម្បីឱ្យការវាយតម្លៃលើភស្តុតាងដែលភាគីបានធ្វើការបញ្ជាក់ឱ្យមានប្រសិទ្ធភាព ហេតុនេះការវាយតម្លៃលើភស្តុតាងត្រូវបានបែងចែកជា៣ចំណុច **១.១. កម្មវត្ថុនៃការបញ្ជាក់ភស្តុតាង ១.២. អង្គហេតុដែលមិនបញ្ជាក់ភស្តុតាង និង១.៣. គោលការណ៍នៃការជំនឿទុកចិត្តដោយសេរី** ។

### ១.១. កម្មវត្ថុនៃការបញ្ជាក់ភស្តុតាង

ជាគោលការណ៍ នៅក្នុងនីតិវិធីបណ្តឹង កម្មវត្ថុនៃការបញ្ជាក់ភស្តុតាង គឺជាអង្គហេតុ។ ប៉ុន្តែនៅក្នុងករណីខ្លះក៏មានវិធាននៃបទពិសោធន៍ និងបញ្ញត្តិនៃច្បាប់ ក៏អាចជាកម្មវត្ថុនៃការបញ្ជាក់ភស្តុតាងផងដែរ។ កម្មវត្ថុនៃការបញ្ជាក់ភស្តុតាងមានដូចជា អង្គហេតុ វិធានតាមបទពិសោធន៍ និងតាមបញ្ញត្តិច្បាប់។

#### ក. អង្គហេតុ

អង្គហេតុដែលត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង មិនមែនត្រឹមតែជាអង្គហេតុផ្ទាល់ប៉ុណ្ណោះទេ គឺរួមបញ្ចូលទាំងអង្គហេតុប្រយោល និងអង្គហេតុបន្ទាប់បន្សំផងដែរ។ ក៏ប៉ុន្តែអង្គហេតុដែលភាគីបានសារភាពនៅតុលាការ និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែងមិនចាំបាច់ធ្វើការបញ្ជាក់ទេ (មាត្រា១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ឧទាហរណ៍៖** ករណីធ្លាក់យន្តហោះ ឬ អគ្គីភ័យណាមួយដែលគេដឹងឮគ្រប់គ្នា។

[12] មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

### ខ. វិធានតាមបទពិសោធន៍

វិធានតាមបទពិសោធន៍ គឺជាចំណេះដឹង ឬវិធានដែលទាក់ទងទៅនឹងទំនាក់ទំនងហេតុផល ឬចរិកលក្ខណៈ នៃហេតុការណ៍ ឬវត្ថុផ្សេងៗ ដែលបានមកពីបទពិសោធន៍នីមួយៗ។ វិធានតាមបទពិសោធន៍នៅក្នុងបណ្ដឹង ត្រូវបានយកទៅប្រើជាទីសំអាងដ៏សំខាន់ នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋាន ដោយផ្អែកលើអង្គហេតុប្រយោល ឬអង្គហេតុចម្បងផ្សេងៗគ្នាដោយតក្កវិទ្យា។ ជាធម្មតាមនុស្សម្នាក់ៗ រួមទាំងចៅក្រមផងក៏តែងតែមានបទពិសោធន៍ ចំពោះបញ្ហាធម្មតាដែលទាក់ទងនឹងជីវភាពសាមញ្ញក្នុងការរស់នៅ។ ប៉ុន្ដែមានបទពិសោធន៍មួយចំនួនដែលមានតែអ្នកជំនាញទេ ទើបអាចយល់ដឹងបាន ហេតុនេះត្រូវតែឱ្យមានការបញ្ជាក់ជាពិសេសទៅលើភស្តុតាង (អង្គហេតុប្រយោល) សិនទើបអាចយកមកប្រើប្រាស់ដើម្បីទទួលស្គាល់អង្គហេតុនោះបាន។ **ឧទាហរណ៍៖** នៅលើបញ្ហានេះ គឺក្នុងករណីដែលវិធានតាមបទពិសោធន៍ទូទៅចំពោះចម្ងាយនៃស្នាមកង់រថយន្តដែលបានបន្សល់ទុកដោយការចាប់ហ្វ្រាំងនៅពេលបើកបរក្នុងល្បឿនជាក់លាក់ណាមួយ ត្រូវបានយកទៅប្រើប្រាស់ដើម្បីធ្វើការសន្និដ្ឋានអំពីល្បឿនរត់នៃរថយន្ត ដោយផ្អែកលើចម្ងាយជាក់ស្ដែងនៃស្នាមកង់រថយន្តដែលបានបន្សល់ទុកនៅលើផ្ទៃនៃថ្នល់កៅស៊ូនៅពេលចាប់ហ្វ្រាំង ឬឧទាហរណ៍ម្យ៉ាងទៀតដែលមានទំនាក់ទំនងហេតុនឹងផលរវាង អាវុធ ចម្ងាយ ល្បឿននៃគ្រាប់ ស្លាកស្នាមទំហំនៃគ្រាប់ជាអាទិ៍...។

ចំពោះវិធានតាមបទពិសោធន៍ ដែលប្រជាជនសាមញ្ញស្គាល់គ្រប់គ្នាថាជាសុភវិនិច្ឆ័យ ចៅក្រមអាចប្រើប្រាស់វិធានទាំងនោះ ដើម្បីទទួលស្គាល់អង្គហេតុណាមួយ ដោយមិនផ្អែកលើភស្តុតាងបាន។ ផ្ទុយទៅវិញ ចំពោះវិធានតាមបទពិសោធន៍ដែលមានតែអ្នកជំនាញប៉ុណ្ណោះដែលអាចដឹងបានតាមធម្មតាត្រូវទទួលស្គាល់វិធាននោះដោយផ្អែកលើភស្តុតាងសិន ទើបអាចយកវិធានទាំងនោះទៅប្រើប្រាស់ដើម្បីទទួលស្គាល់អង្គហេតុបាន។ វិធានតាមបទពិសោធន៍អំពីល្បឿនរបស់រថយន្ត លក្ខណៈនៃផ្ទៃថ្នល់កៅស៊ូ និងចម្ងាយនៃស្នាមកង់រថយន្តដែលបណ្ដាលមកពីការចាប់ហ្វ្រាំងបន្ទាន់ ដូចបានលើកឡើងខាងលើ ក៏ជាឧទាហរណ៍នៃវិធានតាមបទពិសោធន៍ជំនាញដែរ។ នៅក្នុងករណីជាច្រើន ដើម្បីបញ្ជាក់អំពីវិធាននៃបទពិសោធន៍ គេប្រើប្រាស់ប្រភេទនៃការពិនិត្យភស្តុតាង ដែលគេហៅថា **កោសលវិច័យ**[13]។

### គ. បញ្ញត្តិច្បាប់

ជាទូទៅ ចៅក្រម គឺជាអ្នកមានសមត្ថភាព ចំណេះដឹងវិជ្ជាជីវៈច្បាប់ ដូចនេះចៅក្រមត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ និងចេញសេចក្ដីសម្រេចតាមបញ្ញត្តិច្បាប់ ដោយផ្អែកតាមចំណេះដឹងផ្ទាល់ខ្លួន តាម

[13] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគ១

ការអនុវត្តជាក់ស្តែងចៅក្រមក៏អនុវត្តបែបនេះផងដែរ។ ប៉ុន្តែច្បាប់មួយចំនួន ដូចជាច្បាប់បរទេស ឬច្បាប់ពិសេស ឬទំនៀមទម្លាប់ខ្លះ ចៅក្រមមិនអាចមានចំណេះដឹងលើគ្រប់វិស័យនោះទេ ហេតុនេះហើយទើបទាមទារឱ្យមានការបញ្ជាក់ភស្តុតាង អំពីច្បាប់ ឬទំនៀមទម្លាប់ទាំងនោះ។

### ១.២. អង្គហេតុដែលមិនបញ្ជាក់ភស្តុតាង

ជាគោលការណ៍ អង្គហេតុដែលភាគីបានធ្វើការអះអាង គឺទាមទារឱ្យមានការបញ្ជាក់ដោយភស្តុតាង ប៉ុន្តែទោះបីជាអង្គហេតុនោះ គឺជាកម្មវត្ថុនៃការបញ្ជាក់ក៏ដោយ ក៏មិនមែនរាល់អង្គហេតុទាំងអស់ដែលបានអះអាងដោយភាគី សុទ្ធតែត្រូវបញ្ជាក់នោះទេ។ ហេតុនេះហើយទើបអង្គហេតុមួយចំនួនដែលពុំមានវិវាទរវាងភាគីដែលមានដូចជា អង្គហេតុដែលបានសារភាព អង្គហេតុដែលត្រូវបានចាត់ទុកថាបានសារភាព និងអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែង តុលាការមិនចាំបាច់ធ្វើការបញ្ជាក់អង្គហេតុទាំងនោះដោយភស្តុតាងទៀតទេ ហើយត្រូវយកអង្គហេតុទាំងនោះទៅធ្វើជាមូលដ្ឋាននៃការចេញសាលក្រម ។

#### ក. ការសារភាពតាមផ្លូវតុលាការ

ការសារភាពតាមផ្លូវតុលាការ សំដៅទៅលើសេចក្តីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់ថាអង្គហេតុណាមួយដែលធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន ហើយដែលបានអះអាងដោយភាគីម្ខាងទៀតគឺជាការពិតនៅចំពោះមុខតុលាការ ក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវបានកត់សម្គាល់ថា ការសារភាពនូវអង្គហេតុ និងការបកស្រាយនូវអង្គហេតុ និងការអនុវត្តច្បាប់ត្រូវគ្នា។ ដើម្បីអាចធ្វើការទទួលស្គាល់ថាជាការសារភាពតាមរយៈសេចក្តីថ្លែងការណ៍របស់ភាគីទាំងសងខាងត្រូវតែមានភាពស៊ីសង្វាក់គ្នា ប៉ុន្តែគេមិនចាំបាច់គិតអំពីលំដាប់មុនក្រោយនៃសេចក្តីថ្លែងការណ៍របស់ភាគីទាំងសងខាងនោះទេ។ ទោះបីជា ក្នុងករណីដែលភាគីម្ខាងបានធ្វើសេចក្តីថ្លែងការណ៍មួយដែលធ្វើឱ្យខូចប្រយោជន៍របស់ខ្លួន ហើយក្រោយមកទើបភាគីម្ខាងទៀតបានលើកឡើងក៏ដោយ ក៏អាចទទួលស្គាល់ថាជាការសារភាពដែរ (នេះហៅថាការសារភាពមុន)[14]។ ម្យ៉ាងវិញទៀតចំពោះសេចក្តីថ្លែងការណ៍ទទួលស្គាល់អំពីអត្ថិភាពនៃសិទ្ធិ ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ភាគីម្ខាង ចំពោះការអះអាងរបស់ភាគីម្ខាងទៀតថាជាការពិត គឺការទទួលស្គាល់ការទាមទារតាមផ្លូវបណ្តឹងដែលមិនមែនជាការសារភាពអង្គហេតុឡើយ[15]។

[14] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១

[15] សៀវភៅមេរៀនរបស់សាស្ត្រា ហ៊ី សោភា

ការទទួលស្គាល់ការទាមទារតាមផ្លូវបណ្ដឹង មានអត្ថិភាពអាចជាមូលហេតុនៃការបញ្ចប់បណ្ដឹង[16]។

កម្មវត្ថុនៃការសារភាព គឺអង្គហេតុ។ ការសារភាពតាមផ្លូវតុលាការ មានអានុភាពពីរ គឺ អានុភាពចំពោះតុលាការ និងអានុភាពចំពោះភាគី។ ការសារភាពតាមផ្លូវតុលាការមានអានុភាពចងតុលាការ ហើយធ្វើឱ្យតុលាការបាត់បង់សិទ្ធិវិនិច្ឆ័យដោយផ្អែកលើភស្តុតាង (មាត្រា១២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា)។ ហើយការសារភាពតាមផ្លូវតុលាការ មានអនុភាពចងភាគី ដែលបានសារភាព ពោលគឺមិនអនុញ្ញាតឱ្យភាគីនោះដកការសារភាព ហើយមិនអាចធ្វើការអះអាងផ្ទុយពីការសារភាពលើកមុនបានឡើយ។ ការហាមឃាត់នេះធ្វើឡើងដើម្បីជៀសវាងនូវភាពច្របូកច្របល់ក្នុងនីតិវិធី ដែលនាំឱ្យមានការយឺតយ៉ាវដល់ការវិនិច្ឆ័យបណ្ដឹង និងធ្វើឱ្យមានការខូចខាតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀត (ផលប្រយោជន៍ក្នុងការមិនចាំបាច់បញ្ជាក់អំពីអង្គហេតុនោះ)។ ហេតុនេះ បើផ្អែកតាមគោលការណ៍នៃការហាមការក្រឡាស់សំដី (ការហាមការធ្វើសេចក្ដីថ្លែងការណ៍ផ្ទុយនឹងសេចក្ដីថ្លែងការណ៍មុន) ដោយហេតុថាការសារភាពតាមផ្លូវតុលាការមិនអាចធ្វើការដកវិញ ឬធ្វើការផ្លាស់ប្ដូរតាមអំពើចិត្តបានទេ។ ប៉ុន្តែក៏មានករណីដែលភាគីអាចធ្វើការដកការសារភាពរបស់ខ្លួនវិញបានដែរ គឺនៅក្នុងករណីដែលភាគីម្ខាងទៀតពុំមានការតវ៉ា ឬការសារភាពដែលធ្វើឡើងដោយផ្ទុយនឹងការពិត ដោយសារតែមានការភាន់ច្រឡំ និងការសារភាពដែលបណ្ដាលមកពីសកម្មភាពបទល្មើសរបស់អ្នកដទៃ[17]។ បើទោះបីជាមានការសារភាពតាមផ្លូវតុលាការក៏ពិតមែន ប៉ុន្តែចំពោះការបកស្រាយ និងការអនុវត្តច្បាប់ គឺជាមុខងាររបស់ចៅក្រម ហេតុនេះហើយ ទោះបីជាក្នុងករណីដែលការអះអាងរបស់ភាគីទាំងសងខាងមានអត្ថិភាពផ្នែកច្បាប់ ឬការបកស្រាយច្បាប់នោះ មានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុក៏ដោយ ក៏មិនអាចទទួលស្គាល់ថាជាការសារភាពឡើយ។ បញ្ហាគឺសេចក្ដីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់ថា ការអះអាងរបស់ភាគីម្ខាងទៀតអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត គឺជាការពិត។ សេចក្ដីថ្លែងការណ៍ដែលភាគីម្ខាងទទួលស្គាល់អត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលភាគីម្ខាងទៀតលើកឡើងការទាមទារនៅក្នុងបណ្ដឹង **(ឧទាហរណ៍៖ បណ្ដឹងទាក់ទងនឹងពាក្យសុំដីកាសម្រេចក្នុងរឿងរក្សាការពារ ភាគីដែលដាក់ពាក្យសុំត្រូវបញ្ជាក់អំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ)**។ ម្យ៉ាងវិញទៀត សេចក្ដីថ្លែការណ៍ដែលភាគីម្ខាងទៀតទទួលស្គាល់អំពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាបុរេលក្ខខណ្ឌនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្ដឹង (ហៅថា ទំនាក់ទំនងគតិយុត្តដែលត្រូវបានសម្រេចជាមុន) ដែលភាគីម្ខាងទៀតបានលើកឡើង គេហៅថា "ការសារភាពអំពីសិទ្ធិ"។ **ជាឧទាហរណ៍៖** នៅក្នុងបណ្ដឹងទាមទារឱ្យប្រគល់

[16] មាត្រា ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[17] មាត្រា ១២៣ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

វត្ថុត្រឡប់មកវិញដោយផ្អែកលើកម្មសិទ្ធិ ភាគីដែលធ្វើការទាមទារត្រូវបញ្ជាក់អំពីកម្មសិទ្ធិរបស់ខ្លួនទៅលើវត្ថុដែលជាកម្មវត្ថុនៃការទាមទារនោះ។ ក្នុងករណីបែបនេះ ប្រសិនបើចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនទទួលស្គាល់ថាដើមចោទពិតជាម្ចាស់កម្មសិទ្ធិករនៃវត្ថុនោះមែន សេចក្តីថ្លែងការណ៍នេះគឺជាការសារភាពអំពីសិទ្ធិ ក្នុងករណីនេះចុងចម្លើយត្រូវធ្វើការអះអាងអំពីមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់វត្ថុនោះ ចំពោះម្ចាស់កម្មសិទ្ធិករ[18] ដូចជាសិទ្ធិជួលវត្ថុនោះ ជាដើម។

**ខ. ការចាត់ទុកថាបានសារភាព**

នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើភាគីមិនបានបង្ហាញច្បាស់លាស់នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានធ្វើការអះអាងទេ ភាគីដែលមិនធ្វើការតវ៉ានោះត្រូវចាត់ទុកថាបានសារភាពអំពីអង្គហេតុនោះ[19]។ ទោះបីជាយ៉ាងនេះក្តី ការចាត់ទុកថាបានសារភាពបែបនេះមិនត្រូវបានយកមកអនុវត្តឡើយ ប្រសិនបើក្នុងករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តីដោយយល់ឃើញថា ភាគីដែលមានសិទ្ធិតវ៉ាបានធ្វើការតវ៉ាអំពីអង្គហេតុនោះ[20]។ ការចាត់ទុកថាបានសារភាព គឺមានអានុភាពចងតុលាការដូចទៅនឹងការសារភាពដែរ ប៉ុន្តែការចាត់ទុកថាបានសារភាពពុំមានអានុភាពចងភាគីដូចទៅនឹងការសារភាពនោះទេ មានន័យថាភាគីដែលបានធ្វើការអះអាង តវ៉ាអំពីអង្គហេតុនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅពេលក្រោយបាន លើកលែងតែការតវ៉ា (ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន) នេះមិនត្រូវនឹងពេលសមរម្យ ដូចមានបញ្ញត្តិនៅមាត្រា ៩៤ ស្តីពីការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យនៃក្រមនីតិវិធីរដ្ឋប្បវេណី។ លើសពីនេះ ក៏នៅមានករណីផ្សេងមួយទៀតផងដែរ ដែលជាគោលការណ៍ត្រូវបានតុលាការចាត់ទុកថាបានសារភាពនោះ គឺក្នុងករណីដែលចុងចម្លើយមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថាចុងចម្លើយបានធ្វើការសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដោយទាក់ទងនឹងអង្គហេតុ[21] គឺជាការពិត។

[18] មាត្រា ១៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[19] មាត្រា ៩៦ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[20] មាត្រា ៩៦ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[21] មាត្រា ២០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

**គ. អង្គហេតុជាក់ស្តែង**

អង្គហេតុជាក់ស្តែង គឺជាអង្គហេតុដែលគ្រប់គ្នាបានដឹងឮជាសាធារណៈ និង អង្គហេតុដែលតុលាការអាចដឹងបាននៅក្នុងការបំពេញតួនាទីវិជ្ជាជីវៈរបស់ខ្លួន។ អង្គហេតុទាំងនេះពុំទាមទារឱ្យមានការបញ្ជាក់ភស្តុតាងឡើយ។

អង្គហេតុដែលគ្រប់គ្នាបានដឹងឮជាសាធារណៈ គឺជាព្រឹត្តិការណ៍ដែលល្បីៗក្នុងប្រវត្តិសាស្រ្ត ដូចជាគ្រោះមហន្តរាយធម្មជាតិ ឬឧប្បត្តិហេតុធំៗដទៃទៀត ដែលសាធារណៈជនទូទៅបានដឹងឮ។ ប៉ុន្តែទោះបីជាមានករណីខ្លះអង្គហេតុដែលគេបានដឹងឮគ្រប់ៗគ្នាក៏ដោយ ក៏វាអាចនឹងផ្ទុយពីការពិតបានផងដែរ ដូចនេះប្រសិនបើមានវិវាទចំពោះអង្គហេតុនេះ តុលាការអាចអនុញ្ញាតឱ្យផ្តល់នូវភស្តុតាងផ្ទុយចំពោះអង្គហេតុនោះបាន។

ចំណែកឯអង្គហេតុដែលតុលាការអាចដឹងបាននៅក្នុងការបំពេញតួនាទីវិជ្ជាជីវៈ គឺជាអង្គហេតុដែលចៅក្រមទទួលបន្ទុកធ្វើការជម្រះក្តី អាចដឹងបាននៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដូចជាកាលបរិច្ឆេទនៃការបញ្ជូនពាក្យបណ្តឹង ការបង្ហាញឆន្ទៈតាមច្បាប់សារធាតុនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ការសម្រេចសេចក្តីដោយចៅក្រមនេះនៅក្នុងរឿងក្តីផ្សេង និង ការប្រកាសអំពីធនក្ស័យដែលធ្វើឡើងក្រោមរូបភាពជាការប្រកាសជាសាធារណៈនៅតុលាការ ជាអាទិ៍។ អង្គហេតុដែលចៅក្រមបានដឹង នៅក្រៅវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួន (អង្គហេតុដែលចៅក្រមដឹងដោយខ្លួនឯង) មិនរាប់បញ្ចូលទៅក្នុងប្រភេទនៃអង្គហេតុទេ។

## ១.៣. គោលការណ៍នៃជំនឿទុកចិត្តដោយសេរី និងការវាយតម្លៃ

**ក. អត្ថន័យនៃគោលការណ៍ជំនឿទុកចិត្តដោយសេរី**

គោលការណ៍សេរីភាពនៃជំនឿទុកចិត្ត គឺជាគោលការណ៍សម្រាប់ការវិនិច្ឆ័យ អំពីការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុ ដែលបានអះអាងដោយភាគី ដោយជំនឿទុកចិត្តរបស់ចៅក្រមតាមរយៈការអនុញ្ញាតឱ្យចៅក្រមនោះ ធ្វើការវាយតម្លៃ និងវិនិច្ឆ័យ ដោយសេរីទៅលើលទ្ធផល ដែលបានមកពីការពិនិត្យ (បញ្ជាក់) ភស្តុតាង និងការទាញហេតុផលដោយផ្ទាល់មាត់[22]។ គោលការណ៍ជំនឿទុកចិត្ត ត្រូវបានច្បាប់ទំនើបនៃសង្គមប្រជាធិបតេយ្យ ជ្រើសរើសយកជាគោលការណ៍មូលដ្ឋាននៃការវិនិច្ឆ័យរឿងក្តី ជំនួសឱ្យ "គោលការការណ៍បញ្ជាក់ភស្តុតាងដែលច្បាប់បានកំណត់"។ តាមគោលការណ៍បញ្ជាក់ភស្តុតាងដែលច្បាប់បានកំណត់ គឺជាគោលការណ៍ដែលចងចៅក្រមដោយកំណត់ជាមុន ដោយការកំណត់របស់ច្បាប់នូវតម្លៃនៃឯកសារភស្តុតាង ដូចជាភស្តុតាង

[22] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ដែលមានក្នុងលិខិតសាធារណៈ មានតម្លៃជាងភស្តុតាងដែលមាននៅក្នុងលិខិតឯកជន ភស្តុតាងដែលមានតម្លៃជាងឯកសារកត់ត្រាចម្លើយ ឬដើម្បីទទួលស្គាល់អង្គហេតុណាមួយត្រូវមានចម្លើយដូចគ្នារបស់សាក្សីពីររូបជាអាទិ៍......។

នៅក្នុងសង្គមបច្ចុប្បន្ន ដែលកាន់តែមានសភាពស្មុគស្មាញទៅៗ មិនអាចធ្វើការបំភ្លឺអំពីភាពពិតនៃរឿងក្តីដោយវិធីបញ្ជាក់ភស្តុតាងដែលច្បាប់បានកំណត់ទៀតឡើយ។ ដូចនេះគោលការណ៍សេរីភាពនៃជំនឿទុកចិត្ត ដែលពឹងពាក់ទៅលើការវិនិច្ឆ័យដោយសេរី ដោយផ្អែកទៅលើទំនុកចិត្ត លើគំនិត ទស្សនៈ បទពិសោធន៍ មនសិការ និង សីលធម៌វិជ្ជាជីវៈរបស់ចៅក្រម ត្រូវបានច្បាប់របស់បណ្តាប្រទេសនានា ដែលមានលក្ខណៈទំនើបទទួលយក និងធ្វើការអនុវត្ត[23]។

**ខ. ការវាយតម្លៃដោយសេរីលើភស្តុតាង**

ភាគីដែលបានដាក់នូវភស្តុតាង គឺត្រូវចង្អុលបង្ហាញនូវអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងដែលខ្លួនបានអះអាង។ ហើយការចង្អុលបង្ហាញនេះពុំចងតុលាការក្នុងទទួលស្គាល់អង្គហេតុដែលជាកម្មវត្ថុក្នុងការបញ្ជាក់ដោយភស្តុតាងនោះទេ ពោលគឺតុតាលាការត្រូវប្រើគោលការណ៍ជំនឿទុកចិត្តដោយសេរី ក្នុងការទទួលស្គាល់អង្គហេតុដែលភាគីបានធ្វើការអះអាង។ នៅក្រោមគោលការណ៍ជំនឿទុកចិត្តដោយសេរី ឯកសារនៃភស្តុតាងដែលបានមកពីការពិនិត្យភស្តុតាង មានអានុភាពជាភស្តុតាង ឬមានតម្លៃត្រឹមកម្រិតណាមួយ ឬមានប្រយោជន៍ ឬគ្មានប្រយោជន៍សម្រាប់ការបញ្ជាក់ការពិតនៃរឿងក្តីត្រូវបានប្រគល់ឱ្យចៅក្រមដើម្បីធ្វើការវាយតម្លៃដោយសេរី។

ជាទូទៅ ភាគីតែងតែស្នើសុំដាក់បញ្ចូលនូវភស្តុតាង ដើម្បីអាចបញ្ជាក់នូវអង្គហេតុដែលមានប្រយោជន៍ដល់ខ្លួន។ ប៉ុន្តែក្រោមគោលការណ៍ជំនឿទុកចិត្តដោយសេរីនេះ នាំឱ្យគោលបំណងរបស់ភាគីមិនអាចចងតុលាការបានទេ។ ហើយចំពោះការវាយតម្លៃលើភស្តុតាងតុលាការត្រូវឈរលើគោលការណ៍ជំនឿទុកចិត្តដោយសេរី ផ្អែកលើបទពិសោធន៍ និងមនសិការរបស់ខ្លួន ដោយយល់ឃើញថាការដាក់ភស្តុតាងមិនអាចអោយតុលាការសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុដែលជាកម្មវត្ថុនៃការបញ្ជាក់។ តុលាការនិងធ្វើការវាយតម្លៃ ដោយមិនទទួលស្គាល់អង្គហេតុដែលភាគីបាន អះអាងនោះទេ។ ហេតុនេះការដាក់នូវភស្តុតាងណាមួយ គឺទាមទារឱ្យភាគីធ្វើការបញ្ជាក់យ៉ាងច្បាស់អំពីទំនាក់ទំនងរវាងភស្តុតាង និងអង្គហេតុដែលបានកើតឡើងនោះឱ្យមានភាពស៊ីសង្វាក់គ្នា ទើបតុលាការអាចធ្វើការពិចារណាអំពីអត្ថិភាពនៃភស្តុតាងដែលភាគីបានដាក់ជូនតុលាការនោះ។

[23] សៀវភៅមេរៀន នីតិវិធីរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ ហ៊ី សោភា

### គ. ការកម្រិតចំពោះគោលការណ៍នៃជំនឿទុកចិត្តដោយសេរី

បើទោះបីជាចៅក្រមមានសេរីភាពក្នុងការវាយតម្លៃ ឬធ្វើការសន្និដ្ឋានថាមាន ឬគ្មានអង្គហេតុណាមួយ ប៉ុន្តែមិនមានន័យថាចៅក្រមត្រូវបានអនុញ្ញាតឱ្យទទួលស្គាល់អង្គហេតុ ឬបង្កើតទំនុកចិត្តតាមតែទំនើងចិត្តរបស់ខ្លួននោះឡើយ។ ដោយក្រោមគោលការណ៍ជំនឿទុកចិត្តដោយសេរី ការទទួលស្គាល់អង្គហេតុ ការបង្កើតទំនុកចិត្ត ត្រូវតែឆ្លងកាត់ដំណាក់កាលនៃការពិនិត្យ ការវាយតម្លៃ និងសន្និដ្ឋានប្រកបដោយសីលធម៌វិជ្ជាជីវៈ ហើយដែលស្របនឹងរូបមន្តនៃបទពិសោធន៍រួមទាំងទ្រឹស្តីផងដែរ។ ការវាយតម្លៃ ការសន្និដ្ឋានមិនសមស្របតាមតម្រូវការខាងលើ ពោលគឺការសន្និដ្ឋានទទួលស្គាល់អង្គហេតុដែលមិនត្រឹមត្រូវ ហើយខុសច្បាប់ នោះតុលាការនៃការជំនុំជម្រះជាន់ខ្ពស់នឹងធ្វើការកែតម្រូវ ពោលគឺ កាលបើតុលាការធ្វើការទទួលស្គាល់អង្គហេតុដែលជាក់ស្តែងធ្វើឱ្យគេឃើញថាពុំសមស្រប នោះសេចក្តីសម្រេចនឹងក្លាយជាកម្មវត្ថុនៃការកែប្រែនៅតុលាការនៃបណ្តឹងសារទុក្ខ។ ដូចនេះសបញ្ជាក់ឱ្យឃើញថា ទោះបីជាចៅក្រមមានសិទ្ធិយ៉ាងពេញលេញក្នុងការទទួលស្គាល់អង្គហេតុណាមួយដែលភាគីបានលើកឡើងក៏ពិតមែន តែសិទ្ធិនេះក៏ត្រូវបានគេកម្រិតផងដែរ ប្រសិនបើការទទួលស្គាល់អង្គហេតុណាមួយនោះ ធ្វើឡើងដោយមិនត្រឹមត្រូវ។

## ផ្នែកទី២ ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង

ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺជារបបមួយដែលអនុញ្ញាតឱ្យធ្វើការវិនិច្ឆ័យអំពីការកើតឡើង ឬមិនកើតឡើងនូវអានុភាពគតិយុត្តជាក់លាក់ណាមួយ ដោយសន្មត់ឱ្យភាគីណាម្ខាងចាញ់ប្រៀប ក្នុងករណីដែលមិនអាចកំណត់បានអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិរបស់ខ្លួនតាមនីតិវិធីបណ្តឹងនៃអង្គហេតុចាំបាច់ដែលសម្រាប់កំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះ។

ការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាង គឺជាសកម្មភាពដែលកើតឡើង ក្នុងករណីដែលមិនមានភាពច្បាស់លាស់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុណាមួយ ដូចនេះត្រូវកំណត់ឱ្យភាគីនៃបណ្តឹងត្រូវទទួលបន្ទុកដើម្បីធ្វើការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុនោះ។ លើសពីនេះភាគីនៃបណ្តឹងក៏ត្រូវបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិរបស់ខ្លួន ព្រមទាំងបញ្ជាក់អំពីភស្តុតាងដែលមានអត្ថិភាព ឬនត្ថិភាពនៃភស្តុតាងដែលខ្លួនបានធ្វើការដាក់ជូនតុលាការដើម្បីធ្វើការពិនិត្យ។ ប៉ុន្តែដោយសារថា ការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវបានប្រើប្រាស់ នៅក្នុងករណីដែលអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុណាមួយនៅតែមានភាពមិនច្បាស់លាស់ បើទោះបីជាបានធ្វើការពិនិត្យភស្តុតាងដោយហ្មត់ចត់យ៉ាងណាក៏ដោយ។ ដូច្នេះហើយ ត្រូវកំណត់ថា ដើមចោទ ឬចុងចម្លើយដែលទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងនៅក្នុងបណ្តឹង។ ចំពោះភាគីដើមចោទ គឺត្រូវធ្វើយ៉ាងណាដើម្បីបញ្ជាក់នូវការពិតនៃអង្គហេតុនោះ ពោលគឺធ្វើយ៉ាងណាឱ្យចៅក្រមមានជំនឿទុកចិត្តថា

អង្គហេតុនោះមានអត្ថិភាព បើពុំដូច្នោះទេ ភាគីដើមចោទមិនអាចសម្រេចនូវគោលបំណងដែលខ្លួនបានទាមទារនៅក្នុងបណ្តឹងឡើយ។ ដោយឡែកភាគីចុងចម្លើយវិញ គឺត្រូវធ្វើការអះអាងតប ដែលអាចធ្វើឱ្យចៅក្រមមានភាពមិនច្បាស់លាស់អំពីអត្ថិភាពនៃអង្គហេតុនោះ គឺមិនចាំបាច់ធ្វើឱ្យចៅក្រមជឿទុកចិត្តថា សេចក្តីថ្លែងការណ៍របស់ខ្លួនជាការពិតនោះទេ ការធ្វើបែបនេះគឺជាការគ្រប់គ្រាន់ក្នុងការសម្រេចគោលបំណងដែលជាអានុភាពនៃការទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងហើយ។ ដូចនេះភស្តុតាងដែលភាគីដើមចោទមានការទទួលខុសត្រូវក្នុងការបញ្ជាក់ ហៅថា "ភស្តុតាងស្រប" ចំណែកឯភស្តុតាងដែលភាគីចុងចម្លើយត្រូវដាក់ជូនតុលាការនោះ ហៅថា "ភស្តុតាងផ្ទុយ"[24]។

### ២.១. ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់

ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ គឺជាការកំណត់តាមច្បាប់ ដែលឱ្យភាគីណាមួយទទួលបន្ទុកក្នុងការបញ្ជាក់ចំពោះអង្គហេតុដោយសំអាងលើភស្តុតាង។ តាមទ្រឹស្តីនៃអង្គហេតុចម្បង ប្រសិនបើអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌនៃបទបញ្ញត្តិសារធាតុត្រូវទទួលស្គាល់ថាពិត ហេតុនេះអានុភាពគតិយុត្តដែលមានចែងនោះក៏កើតមានឡើងដែរ។ មានន័យថា បញ្ញត្តិច្បាប់សារធាតុនីមួយៗមានចែងអំពីលក្ខខណ្ឌគតិយុត្តនានា ដើម្បីឱ្យអានុភាពគតិយុត្តណាមួយកើតមានឡើង ហើយតាមរយៈនេះ គេដឹងថាបញ្ញត្តិច្បាប់សារធាតុនោះ មានគោលគំនិតថា ប្រសិនបើអង្គហេតុណាមួយដែលឆ្លើយតបទៅនឹងលក្ខខណ្ឌគតិយុត្តទាំងនេះកើតមានឡើង នោះនាំឱ្យអានុភាពគតិយុត្តដែលមានចែងនោះត្រូវកើតមានឡើងដែរ។ ដោយជាគោលការណ៍ ភាគីដែលបានអះអាងអំពីអត្ថិភាពនៃសិទ្ធិណាមួយត្រូវតែទទួលបន្ទុកក្នុងការបញ្ជាក់ភស្តុតាងអំពីអង្គហេតុ ដែលជាលក្ខខណ្ឌគតិយុត្តដែលចែងអំពីកំណើតនៃសិទ្ធិនោះដែលបានផ្តល់ផលប្រយោជន៍ដល់ខ្លួន។ **ឧទាហរណ៍៖** មាត្រា ២៤៥ នៃក្រមរដ្ឋប្បវេណី បានកំណត់ថាដើម្បីបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ឱ្យមានអានុភាពត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ បើមិនបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរទេសិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ។ ហេតុនេះអង្គហេតុដែលភាគីត្រូវធ្វើការអះអាងគឺការបង្កើតកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ដូចនេះភស្តុតាងដែលត្រូវធ្វើការបញ្ជាក់គឺ កិច្ចសន្យាបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍។ អង្គហេតុនៃការបង្កើតកិច្ចសន្យានាំឱ្យកើតមានអានុភាពគតិយុត្តនៃសិទ្ធិជួលអចិន្ត្រៃយ៍។ ក្នុងករណីពុំមានបញ្ញត្តិច្បាប់ចែងច្បាស់លាស់ទេ ការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ ត្រូវធ្វើឡើងដោយផ្អែកលើលំដាប់សមហេតុផលនៃការអនុវត្តបញ្ញត្តិនៃច្បាប់សារធាតុ និងទៅតាមវិធីនៃការកំណត់លក្ខខណ្ឌគតិយុត្ត។ ជាក់ស្តែងការបែងចែកការទទួលខុសត្រូវក្នុងការបញ្ជាក់ត្រូវកំណត់ដោយធ្វើការពិចារណាអំពីគោល

[24] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១

នយោបាយ សមធម៌រវាងគូភាគីនៅក្នុងដំណើររឿងក្តី ការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ឬមានភាពងាយស្រួលក្នុងការអះអាងអំពីសិទ្ធិនៅក្នុងនីតិវិធីនៃបណ្តឹង។ ជារួមមក ភាគីនីមួយៗ ត្រូវតែទទួលខុសត្រូវក្នុងការបញ្ជាក់ភស្តុតាងស្តីពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុដែលភាគីនោះបានធ្វើការទាមទារ។

### ២.២. ការសន្មតតាមផ្លូវច្បាប់

ការសន្មតតាមច្បាប់ត្រូវបានចែងឡើងក្នុងគោលបំណងទទួលស្គាល់នូវការកើតឡើងនៃអានុភាពគតិយុត្តដែលកំណត់ដោយច្បាប់ ដែលភាគីបានបំពេញទៅតាមទម្រង់ដែលច្បាប់តម្រូវ។ បើមានបញ្ញត្តិច្បាប់បានចែងថា "ជនដែលបានកាន់កាប់អចលនវត្ថុដោយសន្តិវិធី និងដឹងឮជាសាធារណៈដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល២០ (ម្ភៃ)ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ"[25]។ ដូចនេះបុគ្គលដែលចង់ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ គឺត្រូវបំពេញនូវលក្ខខណ្ឌដែលមាននៅក្នុងបញ្ញត្តិនេះ និងធ្វើការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មនៅពេលដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការសម្រេចតាមពាក្យបណ្តឹងដែលបានធ្វើការអះអាងនោះ។ ឧទាហរណ៍៖ **ក** បានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីអោយតុលាការសម្រេចពីលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ។ ដោយ **ក** បានធ្វើការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម (តាមបញ្ញត្តិមាត្រា ១៦៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា) ដោយគាត់បានចូលទៅកាន់កាប់នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៤ ដោយគាត់បានធ្វើការកាន់កាប់ជាបន្តបន្ទាប់រហូតដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០៣៤ ហើយមានឆន្ទៈយកជាកម្មសិទ្ធិ នឹងបានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ។ ដូចនេះ តាមរយៈការសន្មតដោយច្បាប់ **ក** ត្រូវបានសន្មតថាបានកាប់កាប់ជាបន្តបន្ទាប់ក្នុងរយៈពេល ២០ (ម្ភៃ)ឆ្នាំ ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិ (យោងតាមមាត្រា ២៣៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា)។ ភាគីដែលបានអះអាងអំពីលទ្ធកម្មដោយអាជ្ញាយុកាលនូវលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ តាមការពិតត្រូវបញ្ជាក់ថា បានកាន់កាប់អចលនវត្ថុនោះ ក្នុងអំឡុងពេល ២០ (ម្ភៃ)ឆ្នាំ ជាប់គ្នា ប៉ុន្តែប្រសិនបើភាគីធ្វើការអះអាងអំពីកាលបរិច្ឆេទនៃការចូលកាន់កាប់ និងធ្វើការបញ្ជាក់អង្គហេតុនៃការកាន់កាប់នៅពេល ២០ឆ្នាំ ក្រោយពីនោះក៏អាចសន្មត់តាមផ្លូវច្បាប់ថាបានកាន់កាប់ក្នុងអំឡុងពេលវេលាទាំងពីរនោះ ដូចនេះ តុលាការអាចធ្វើការទទួលស្គាល់អានុភាពគតិយុត្ត ដោយផ្អែកលើការសន្មតតាមផ្លូវច្បាប់ បានផងដែរ។ ការសន្មតតាមផ្លូវច្បាប់ គឺមានអានុភាពខុសគ្នាពីការសន្មតអំពីអង្គហេតុ ក្នុងករណីដែលសន្និដ្ឋានអំពីអង្គហេតុផ្សេងមួយទៀត ដោយប្រើវិធានតាមបទពិសោធន៍ ដូចនេះត្រូវធ្វើការចែកឱ្យដាច់អំពីការ

[25] មាត្រា ១៦២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

សន្មតតាមផ្លូវច្បាប់ និងការសន្មត (សន្និដ្ឋាន) អំពីអង្គហេតុ។ ការសន្មត់អំពីអង្គហេតុ ដោយតាមរយៈវិធានតាមបទពិសោធន៍ គឺដោយគ្រាន់តែទទួលស្គាល់នូវអង្គហេតុ ដោយជំនឿទុកចិត្តដោយសេរីរបស់ចៅក្រមតែប៉ុណ្ណោះ[26] ហើយចំពោះការសន្មតតាមផ្លូវច្បាប់ គឺជាការសន្មតអំពីអានុភាពគតិយុត្តដែលបានកើតឡើងដោយផ្អែកលើគោលការណ៍ច្បាប់។

ចំពោះអានុភាពនៃកាសន្មតតាមផ្លូវច្បាប់ តុលាការអាចធ្វើការទទួលស្គាល់នូវអានុភាពគតិយុត្តដែលភាគីបានធ្វើការអះអាងនោះបាន ប៉ុន្តែភាគីម្ខាងទៀត អាចបដិសេធនូវការសន្មតនោះបានផងដែរ ដោយធ្វើការបញ្ជាក់អំពីនត្ថិភាពនៃអង្គហេតុគតិយុត្តដែលជាលក្ខខណ្ឌចម្បងបាន។ ដូចក្នុងឧទាហរណ៍ខាងលើ ភាគីបានធ្វើការអះអាងអំពីអាជ្ញាយុកាលនូវលទ្ធកម្មកម្មសិទ្ធិ ហេតុនេះនាំឱ្យភាគីដែលជាកម្មសិទ្ធិករ ត្រូវមានបន្ទុកក្នុងការបញ្ជាក់ភស្តុតាងផ្ទុយដើម្បីបញ្ជាក់ពីនត្ថិភាពនៃអង្គហេតុគតិយុត្តដែលជាលក្ខខណ្ឌចម្បង ដោយធ្វើការបញ្ជាក់ថា ក្នុងអំឡុងពេលណាមួយក្នុងរយៈពេល ២០ (ម្ភៃ)ឆ្នាំដែលភាគីធ្វើការអះអាងអំពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិនោះ ត្រូវបានផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មដោយហេតុណាមួយ[27]លើសពីមួយឆ្នាំ (អង្គហេតុរារាំងការកកើតឡើងនៃសិទ្ធិ) ប៉ុន្តែក្នុងករណីនេះភាគីដែលធ្វើការបដិសេធនូវការសន្មតនោះត្រូវធ្វើឱ្យចៅក្រមមានជំនឿថា ភាគីម្ខាងទៀតនោះគឺត្រូវបានផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម នៅក្នុងអំឡុងពេលណាមួយក្នុងរយៈពេល ២០ (ម្ភៃ)ឆ្នាំ នោះមែន។

៚៚✶៛៛

[26] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១

[27] មាត្រា ១៦៧ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣
# នីតិវិធីនៃការពិនិត្យភស្តុតាង
# និង
# ការថែរក្សាការពារភស្តុតាង

# ជំពូកទី៣
# នីតិវិធីនៃការពិនិត្យភស្តុតាង និងការថែរក្សាការពារភស្តុតាង

## ផ្នែកទី១ នីតិវិធីនៃការពិនិត្យភស្តុតាង

### ១.១.ការពិនិត្យភស្តុតាង

តុលាការធ្វើការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ ការពិនិត្យភស្តុតាង គឺជានីតិវិធីដើម្បីទទួលបានធនធានភស្តុតាង ដូចជាចម្លើយជាកសិណសាក្សី មតិយោបល់នៃអ្នកកោសលវិច័យ សេចក្តីថ្លែងការណ៍របស់សាមីភាគី ខ្លឹមសារដែលសរសេរក្នុងឯកសារ លទ្ធផលនៃការពិនិត្យជាអាទិ៍។ ភស្តុតាងដែលតុលាការត្រូវធ្វើការពិនិត្យមានដូចជា កសិណសាក្សី របាយការណ៍អ្នកធ្វើកោសលវិច័យ សាមីភាគី ឯកសារ ឬវត្ថុផ្សេងទៀតដែលមានការទាក់ទងនឹងអង្គហេតុ ជាអាទិ៍។ ចំពោះការពិនិត្យភស្តុតាង តុលាការត្រូវធានានូវឱកាសឱ្យមានវត្តមានរបស់ភាគី ដើម្បីចូលរួមក្នុងការពិនិត្យភស្តុតាង ប៉ុន្តែតុលាការក៏អាចធ្វើការពិនិត្យភស្តុតាងបានដែរ ប្រសិនបើក្នុងករណីដែលភាគីមិនបានចូលខ្លួនតាមកាលបរិច្ឆេទដែលតុលាការបានកំណត់។

ជាគោលការណ៍ ការពិនិត្យភស្តុតាង ត្រូវធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី។ ក៏ប៉ុន្តែប្រសិនបើក្នុងករណី ដែលតុលាការពុំអាចធ្វើការសម្រេចថា ត្រូវទទួលស្គាល់ ឬមិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយភស្តុតាងដែលគូភាគីបានស្នើសុំឱ្យធ្វើការពិនិត្យ ឬបើយល់ឃើញថាមានការចំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យភស្តុតាង ដោយឆន្ទានុសិទ្ធិបាន[28]។ ការស្នើសុំឱ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (យោងតាមមាត្រា ១២៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា) ចំពោះការសម្រេចថាពិនិត្យ ឬមិនពិនិត្យនោះគឺជាឆន្ទានុសិទ្ធិរបស់តុលាការជាអ្នកសម្រេច។ ហើយភាគីដែលបានធ្វើការស្នើសុំឱ្យតុលាការធ្វើការពិនិត្យភស្តុតាងត្រូវតែកំណត់អោយបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ ប្រសិនបើការស្នើសុំឱ្យធ្វើការពិនិត្យភស្តុតាងដែលកំណត់ពុំបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់ទេនោះ ឬការស្នើសុំឱ្យតុលាការធ្វើការពិនិត្យភស្តុតាងដែលមានការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ (តាមមាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ការស្នើសុំដាក់បញ្ចូលភស្តុតាងថ្មីដែលត្រូវបានដាក់នៅក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ទាញហេតុផលដែលនាំឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង (តាមមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី) និងការស្នើសុំឱ្យធ្វើការពិនិត្យភស្តុតាងខុសនូវទម្រង់ តុលាការអាចធ្វើការលើកចោលការស្នើសុំនោះបាន

[28] មាត្រា ១២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

ដោយដីកាសម្រេចលើកចោល។ ម៉្យាងទៀតនៅក្នុងករណីដែលភស្តុតាងគ្មានទំនាក់ទំនងនឹងអង្គហេតុ និងភស្តុតាងឯទៀតដែលតុលាការយល់ឃើញថា មិនចាំបាច់នោះ តុលាការពុំចាំបាច់ធ្វើការពិនិត្យភស្តុតាងនោះទេ (តាមមាត្រា ១២៦ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះតុលាការធ្វើការពិនិត្យភស្តុតាង ដែលតុលាការបានទទួលយកប៉ុណ្ណោះ ដោយមិនធ្វើការពិនិត្យភស្តុតាងដែលត្រូវបានលើកចោលនោះទេ។ ចំពោះភស្តុតាងជាឯកសារ តុលាការអាចធ្វើការពិនិត្យនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលបាន ត្រឹមតែកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តីតែប៉ុណ្ណោះ[29]។

### ១.២.នីតិវិធីនៃការពិនិត្យភស្តុតាងដោយសម្ភូហវិធី

នីតិវិធីនៃការពិនិត្យភស្តុតាង ត្រូវបានធ្វើឡើងតាមស្នើសុំរបស់ភាគី ហើយការពិនិត្យភស្តុតាងអាចធ្វើឡើងដោយសម្ភូហវិធីដែលមានភស្តុតាងជាច្រើនដើម្បីឱ្យតុលាកាធ្វើការពិនិត្យដោយភស្តុតាងដែលនឹងត្រូវធ្វើការពិនិត្យមានដូចជាការសាកសួរសាក្សី ការសាកសួរសាមីភាគី កោសលវិច័យភស្តុតាងជាឯកសារ និងការត្រួតពិនិត្យ។ ហើយភស្តុតាងដែលត្រូវបានធ្វើការពិនិត្យទាំងនេះគឺសុទ្ធតែជាភស្តុតាងដែលតុលាការធ្វើការទទួលយក ដោយដីកាសម្រេចទទួលយកភស្តុតាង ដែលភាគីបានធ្វើការស្នើសុំឱ្យពិនិត្យ។

### ១.២.១.សាក្សី

សាក្សី គឺជាតតិយជន (ក្រៅពីភាគី) ដែលត្រូវបានតុលាការបង្គាប់ឱ្យធ្វើសេចក្តីថ្លែងការណ៍ជូនតុលាការ ស្តីអំពីអង្គហេតុនៃអតីតកាលដែលខ្លួនបានជួបប្រទះដោយខ្លួនឯង។ សេចក្តីរាយការណ៍របស់សាក្សី ហៅថា ចម្លើយជាកសិណសាក្សី រីឯការពិនិត្យភស្តុតាងដើម្បីយកចម្លើយជាកសិណសាក្សីនោះ គឺជាការសាកសួរសាក្សី។ តាមបញ្ញត្តិនៃក្រមនីតិវីធីរដ្ឋប្បវេណី ជនទាំងអស់ដែលស្ថិតនៅក្រោមសិទ្ធិជំនុំជម្រះរបស់តុលាការរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវមានករណីកិច្ចធ្វើជាសាក្សី[30]។

#### ក.ការសាកសួរសាក្សី

តុលាការត្រូវសាកសួរសាក្សីអំពីអង្គហេតុវិវាទប្រកបដោយជំហរអព្យាក្រឹត្យ ហើយចៅក្រមអាចសាកសួរសាក្សីបានចំពោះអង្គហេតុមួយចំនួនដែលមិនស្វរច្បាស់។ ចំពោះការសាកសួរនេះ តុលាការត្រូវធ្វើការវាយតម្លៃប្រកបដោយការជឿជាក់លើចម្លើយរបស់សាក្សី ដោយពិចារណាគ្រប់ចម្លើយរបស់សាក្សីដែលបានឆ្លើយនៅក្នុងលំដាប់ ធ្វើដោយចៅក្រម ដោយភាគី និងភស្តុតាងផ្សេងៗ[31]។

---

[29] មាត្រា ១០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[30] មាត្រា ១៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[31] សៀវភៅមេរៀន ស្តីពីក្រមរដ្ឋប្បវេណី និងសង្ខេប នីតិវិធីរដ្ឋប្បវេណី របស់លោក សៀង មុន្នីរ័ត្ន ជាសិស្សចៅក្រមជំនាន់៣

ក្នុងករណីដែលសាក្សីមិនមានវត្តមានចំពោះមុខតុលាការតាមការកោះហៅ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចបង្គាប់អោយនាំខ្លួនសាក្សីនោះបាន។ ប្រសិនបើសាក្សីមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន)រៀល បានដោយដីកាសម្រេច[32]។ ប៉ុន្តែសាក្សីក៏អាចបដិសេធក្នុងការផ្តល់ចម្លើយជាកសិណសាក្សីបាន ប្រសិនបើការផ្តល់ចម្លើយជាកសិណសាក្សីនោះ ទាក់ទងនឹងហេតុដែលធ្វើឱ្យសាក្សីខ្លួនឯងផ្ទាល់ ឬ សហព័ទ្ធរបស់សាក្សី ឬញាតិដទៃទៀតរបស់សាក្សីនោះ អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោស ឬជាកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់សាក្សីនោះ។ លើសពីនេះ តុលាការអាចធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបាននៅក្នុងករណីដែលសាក្សីនោះគ្មានករណីយកិច្ចចូលខ្លួនទៅតុលាការ ឬមានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន ឬការចូលខ្លួនរបស់សាក្សីទៅតុលាការបណ្តាលឱ្យមានការចំណាយទៅលើពេលវេលា ឬសោហ៊ុយមិនសមរម្យ ហើយគ្មានការតវ៉ារបស់គូភាគីទៅលើការសាកសួរសាក្សីនៅក្រៅតុលាការនោះ។ តុលាការអាចឱ្យចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលបានការប្រគល់សិទ្ធិ ជាអ្នកទៅធ្វើការសាកសួរសាក្សីនៅក្រៅតុលាការ។ ក្នុងករណីដែល ចៅក្រមទទួលបញ្ជា ឬចៅក្រមទទួលបានការប្រគល់សិទ្ធិ ធ្វើការសាកសួរសាក្សី ចៅក្រមនោះត្រូវបំពេញមុខនាទីរបស់តុលាការ ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ជាគោលការណ៍ ការពិនិត្យភស្តុតាងត្រូវធ្វើជាសាធារណៈនៅក្នុងតុលាការ។ ប៉ុន្តែនៅក្នុងករណីនេះ តុលាការក៏អាចធ្វើការសាកសួរសាក្សីនៅក្រៅតុលាការបានដែរ។ ជាឧទាហរណ៍៖ ក្នុងករណីដែលសាក្សីមិនអាចចូលខ្លួនមកតុលាការបានដោយសារភាពចាស់ជរា ឬដោយសារជម្ងឺ។ នៅពេលធ្វើការសាកសួរសាក្សីនៅក្រៅតុលាការ បើចៅក្រមក្នុងក្រុមប្រឹក្សាចូលរួមទាំងអស់គ្នា នាំឱ្យចំណាយសោហ៊ុយច្រើន ដូច្នេះ គេអនុញ្ញាតឱ្យចៅក្រមម្នាក់ក្នុងចំណោមចៅក្រមក្នុងក្រុមប្រឹក្សាជំនុំជម្រះ (ចៅក្រមដែលទទួលបញ្ជា) ឬចៅក្រមណាដែលមានកន្លែងនៅក្បែរលំនៅដ្ឋានរបស់សាក្សី (ចៅក្រមដែលទទួលការប្រគល់សិទ្ធិ) បំពេញកិច្ចការនេះ[33]។

**ខ.សម្បថ**

ជនទាំងឡាយណា ដែលត្រូវបានតុលាការកោះហៅជាសាក្សី ត្រូវតែបង្ហាញខ្លួននៅចំពោះមុខតុលាការ ហើយត្រូវធ្វើសម្បថ[34] និងមានករណីយកិច្ចផ្តល់ចម្លើយជាកសិណសាក្សី ហើយការធ្វើសម្បថនោះត្រូវធ្វើឡើងនៅមុនការសាកសួរ។ ប៉ុន្តែនៅក្នុងករណីសាក្សីដែលត្រូវសួរ ជាជនដែល

---

[32] មាត្រា ១៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[33] មាត្រា ១៣៦ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[34] មាត្រា ១៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

មានអាយុក្រោម ១៦ (ដប់ប្រាំមួយ)ឆ្នាំ ឬ ជនដែលមិនយល់អំពីអត្ថន័យនៃសម្បថ តុលាការមិនអាចឱ្យសាក្សីនោះធ្វើសម្បថបានឡើយ។ មួយវិញទៀតនៅពេលសាកសួរសាក្សីដែលត្រូវនឹងលក្ខខណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១៣៤ (សិទ្ធបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រសិនបើសាក្សីនោះមិនបានប្រើសិទ្ធិបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី តុលាការអាចមិនឱ្យធ្វើសម្បថបាន។ នៅមុនពេលធ្វើសម្បថ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវពន្យល់អំពីគោលបំណងនៃសម្បថ ហើយប្រាប់ជាមុន អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីភាពក្លែងក្លាយ[35]។ ចំពោះនីតិវិធីក្នុងការធ្វើសម្បថត្រូវ ដឹកនាំធ្វើដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងនៃតុលាការនីមួយៗ ឬនៅទីណាមួយ តាមការព្រមព្រៀងរបស់គូភាគី។ បើមិនមានការចុះសម្រុងគ្នា តុលាការជាអ្នកសម្រេច។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀនធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មក ក្រឡាបញ្ជីត្រូវអានប្រារព្ធវាទ ខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ហេតុយ៉ាងនោះផង[36]។

**គ.វិធីនៃការសាកសួរសាក្សី**

១-ការសាកសួរសាក្សីណាមួយ ត្រូវធ្វើឡើងដោយកំណត់ឱ្យបានច្បាស់លាស់ទៅលើសាក្សីណាមួយនោះ (ដូចជា ឈ្មោះសាក្សី. សាក្សីបានដឹងអំពីចំណុចណាខ្លះ )។

២-អ្នកដែលស្នើសុំសាកសួរសក្សី ត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសាកសួរ។

៣-សាក្សីត្រូវទទួលការកោះហៅយ៉ាងតិច ២ (ពីរ)សប្តាហ៍ មុនថ្ងៃសាកសួរ។

៤-ដីកាកោះហៅសាក្សីត្រូវសរសេរនូវកំណត់សម្គាល់ដូចខាងក្រោម ហើយត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចសាកសួរ :

ក-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី។

ខ-ពេលវេលា និងទីកន្លែងដែលត្រូវចូលខ្លួន។

គ-ទណ្ឌកម្មដែលកំណត់ដោយច្បាប់ នឹងកើតមាន បើមិនចូលខ្លួន។

[35] មាត្រា ១៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[36] ឧបសម្ព័ន្ធ នីតិវិធីក្នុងការធ្វើសម្បថ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

៥-ការសាកសួរសាក្សីត្រូវធ្វើតាមលំដាប់ : ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ភាគីដែលស្នើសុំឱ្យសាកសួរសាក្សីនោះ និងភាគីម្ខាងទៀត។ ចៅក្រមប្រឹក្សាអាចសាកសួរទៅសាក្សីបាន នៅក្រោយពេលបានជម្រាបឱ្យទៅប្រធានក្រុមប្រឹក្សាជំនុំជម្រះឱ្យបានដឹងហើយ។

៦-ប្រសិនបើយល់ឃើញថាត្រឹមត្រូវ តុលាការអាចកែសម្រួលលំដាប់ដែលត្រូវសាកសួរសាក្សីដែលបានកំណត់នៅក្នុងកថាខណ្ឌទី៥ ខាងលើនេះបាន។

៧-សាក្សីមិនអាចឆ្លើយ ដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបានឡើយ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការអនុញ្ញាតពីតុលាការ។

៨-ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចអនុញ្ញាតឱ្យសាក្សីដែលត្រូវបានសាកសួរហើយ ឬសាក្សីដែលបម្រុងនឹងត្រូវសាកសួរ ឱ្យនៅក្នុងសាលសវនាការបាន។

៩-នៅពេលដែលតុលាការទទួលស្គាល់ថា សាក្សីពុំអាចឆ្លើយឱ្យគ្រប់គ្រាន់បាន នៅចំពោះមុខអ្នកសង្កេតការណ៍ណាម្នាក់ ដោយសារតែអ្នកនោះជាហេតុនាំឱ្យមានការភ័យព្រួយ តុលាការអាចបង្គាប់ឱ្យអ្នកអង្កេតការណ៍នោះចេញក្រៅសាលសវនាការ នៅពេលដែលសាក្សីនោះឆ្លើយ។

១០-នៅពេលដែលយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាក្សី និងសាក្សីផ្សេងទៀត នៅពេលជាមួយគ្នាបាន[37] ។

**ឃ. ការកម្រិតនៅលើសំណួរ**

ការសាកសួរទៅលើសាក្សី គឺត្រូវធ្វើតាមនីតិវិធីដូចដែលបានរៀបរាប់ខាងលើ ហើយការសាកសួរនេះត្រូវបានគេកម្រិតនូវសំណួរ។

១-ចំពោះសំណួរ បើអាចធ្វើបាន ត្រូវធ្វើឱ្យដាច់ដោយឡែក និងច្បាស់លាស់។

២-លើកលែងតែករណីដែលមានមូលហេតុត្រឹមត្រូវ មិនអាចសាកសួរបានឡើយនូវសំណួរខាងក្រោមនេះ :

ក-សំណួរដែលប្រមាថមើលងាយ ឬធ្វើឱ្យច្របូកច្របល់ដល់សាក្សីផ្សេង។

ខ-សំណួរនាំមុខ។

គ-សំណួរច្រំដែល។

ឃ-សំណួរដែលគ្មានទំនាក់ទំនងនឹងចំណុចវិវាទ។

ង-សំណួរដែលទាមទារឱ្យថ្លែងយោបល់របស់សាក្សីផ្ទាល់ខ្លួន។

ច-សំណួរដែលទាមទារឱ្យថ្លែងនូវយោបល់អំពីអង្គហេតុដែលសាក្សីពុំបានជួបប្រទះផ្ទាល់។

---

[37] មាត្រា ១៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

៣-តុលាការអាចកម្រិតនូវសំណួរ តាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិបាន នៅពេលដែលយល់ឃើញថា សំណួរនោះផ្ទុយនឹងបញ្ញត្តិដែលមានចែងនៅក្នុងកថាខណ្ឌទី២ខាងលើនេះ។

៤-ភាគីអាចតវ៉ា ចំពោះការកម្រិតដែលធ្វើទៅតាមបញ្ញត្តិនៃកថាខណ្ឌទី៣ខាងលើនេះបាន[38]។

### ១.២.២.ភាគី

#### ក.ការសាកសួរភាគី

ជាដំបូងនៅក្នុងនីតិវិធីនៃការសាកសួរភាគី តុលាការត្រូវសួរអំពី ឈ្មោះ, ថ្ងៃខែឆ្នាំកំណើត,ទីលំនៅបច្ចុប្បន្ន និងមុខរបរ។ ការសាកសួរអំពីអត្តសញ្ញាណនេះមិនមានកំណត់នៅក្នុងច្បាប់ទេ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ចៅក្រមត្រូវតែសាកសួរដើម្បីកុំឱ្យមានការភាន់ច្រឡំលើអត្តសញ្ញាណរបស់បុគ្គល។

ការសាកសួរភាគី គឺជាការពិនិត្យភស្តុតាងដែលធ្វើឡើងដោយតុលាការ ដើម្បីទទួលនូវធនធានភស្តុតាងដោយយកសាមីភាគីមកធ្វើជាភស្តុតាង ដោយឱ្យធ្វើសេចក្តីថ្លែងការណ៍អំពីអង្គហេតុដែលខ្លួនបានជួបផ្ទាល់ តាមរយៈការស្នើសុំ ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ការសាកសួរនេះមានគោលបំណងទទួលយកនូវធនធានភស្តុតាង ដោយយកសាមីភាគីជាកម្មវត្ថុនៃការពិនិត្យ។ ដោយសារតែសាមីភាគី ជាសាក្សីដែលមានព័ត៌មានទាក់ទងនឹងអង្គហេតុជាច្រើនបំផុត ហើយភាគីខ្លួនផ្ទាល់នឹងថ្លែងយោបល់នៃអង្គហេតុណាមួយដែលជាផលប្រយោជន៍ដល់ខ្លួន ដូច្នេះការសាកសួរភាគី គឺជារបៀបបញ្ជាក់មួយដែលឆ្លងកាត់តាមការលំអៀង ដូចនេះចៅក្រមមុននឹងវិនិច្ឆ័យសេចក្តីគួរថ្លឹងថ្លែងពីទម្ងន់នៃភស្តុតាងឱ្យបានច្បាស់លាស់។ ការសាកសួរភាគីតុលាការអាចឱ្យភាគីនោះស្បថបាន។ នៅក្នុងករណីដែលធ្វើការសាកសួរសាមីភាគី បើភាគីណាម្ខាងពុំចូលខ្លួន ឬបដិសេធនូវការធ្វើសម្បថ ឬផ្តល់ចម្លើយ ដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន។ លើសពីនេះ បើភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន)រៀលបានដោយដីកាសម្រេច។ ហើយដីកាសម្រេចនេះអាចប្តឹងទាស់បាន[39]។

វិធីនៃការសាកសួរភាគី គឺអនុវត្តដូចគ្នាទៅនឹងនីតិវិធីនៃការសាកសួរសាក្សីដែរ។ តុលាការអាចធ្វើការសាកសួរសាមីភាគី ជាមួយភាគីម្ខាងទៀត ឬជាមួយនឹងសាក្សីនៅពេលជាមួយគ្នាបាន[40]។ ទោះបីជាអនុវត្តដូចគ្នាទៅនឹងវិធីនៃការសាកសួរសាក្សីក៏ពិតមែន ប៉ុន្តែក៏មានចំនុចមួយចំនួនមិនត្រូវ

[38] មាត្រា ១៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
[39] មាត្រា ១៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
[40] មាត្រា ១៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

បានអនុវត្តចំពោះការសាកសួរសាមីភាគីនោះទេ ដូចជា មាត្រា ១៣៧ (សម្បថ) កថាខណ្ឌទី១ និងកថាខណ្ឌទី៣ មាត្រា ១៣៨ (វិធីសាកសួរសាក្សី) កថាខណ្ឌទី៨ និងកថាខណ្ឌទី១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ជាដើម។

**ខ.ការសាកសួរអ្នកតំណាងដែលច្បាប់បានកំណត់**

ចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលទូទៅ) ដែលធ្វើតំណាងឱ្យអ្នកដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង (អនីតិជន ជននៅក្រោអាណាព្យាបាលទូទៅ ជាដើម) ឬចំពោះអ្នកដែលជាតំណាងនីតិបុគ្គល (នាយកតំណាងក្រុមហ៊ុន ជាដើម) ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងសាមីភាគីខ្លួនផ្ទាល់គឺមិនយោលទៅតាមការសាកសួរសាក្សីជាតតិយជនទេ គឺអនុវត្តនឹងបញ្ញត្តិស្ដីពីការសាកសួរសាមីភាគី។ ប៉ុន្តែក្នុងករណីនេះ ក៏អាចសាកសួរសាមីភាគីផ្ទាល់ (ដែលជាអសមត្ថជនក្នុងការធ្វើបណ្ដឹង) បានផងដែរ[41]។

**១.២.៣.កោសលវិច័យ**

ការធ្វើកោសលវិច័យ គឺជាការពិនិត្យភស្តុតាងដែលតុលាការកំណត់ឱ្យតតិយជន (អ្នកជំនាញខាងកោសលវិច័យ) ដែលមានចំណេះវិជ្ជា និងបទពិសោធន៍ពិសេស ឱ្យធ្វើរបាយការណ៍អំពីវិធានតាមបទពិសោធន៍ដែលខ្លួនបានដឹងតាមចំណេះវិជ្ជារបស់ខ្លួន ឬធ្វើរបាយការណ៍អំពីការវិនិច្ឆ័យ ឬយោបល់ដែលបានមកពីការអនុវត្តវិធានតាមពិសោធន៍ជំនាញ ចំពោះអង្គហេតុជាក់ស្ដែងដែលជាបញ្ហានៅក្នុងបណ្ដឹងនោះ។ តុលាការអាចបង្គាប់អោយធ្វើកោសលវិច័យតាមពាក្យសុំរបស់ភាគីបានដោយភាគីដែលស្នើសុំធ្វើកោសលវិច័យត្រូវភ្ជាប់ជាមួយនូវឯកសារដែលកំណត់ចំណុចដែលសុំអោយធ្វើកោសលវិច័យ[42]។ អ្នកធ្វើកោសលវិច័យ គឺជាសាក្សី ហើយព្រមជាមួយគ្នានោះ ក៏ជាអ្នកជំនួយដល់តុលាការផងដែរ។ តុលាការត្រូវចាត់តាំងអ្នកជំនាញខាងកោសលវិច័យ ជៀសវាងនូវភាពលំអៀង។ នៅក្នុងករណីដែលភាគីណាមួយមានមូលហេតុ ដែលរារាំងសច្ចភាពនៃការធ្វើកោសលវិច័យរបស់អ្នកជំនាញ ភាគីនោះអាចប្ដឹងផាត់ចោលអ្នកជំនាញខាងកោសលវិច័យនោះបាន នៅមុនពេលដែលអ្នកជំនាញនោះ ធ្វើសេចក្ដីសន្និដ្ឋានអំពីចំណុចដែលត្រូវធ្វើកោសលវិច័យ។ ទោះបីជាអ្នកជំនាញបានធ្វើសេចក្ដីសន្និដ្ឋានរួចហើយក្ដី ប្រសិនបើមានមូលហេតុនៃបណ្ដឹងផាត់ចោលបានកើតឡើងនៅពេលក្រោយ ឬភាគីបានដឹងអំពីមូលហេតុ ណាមួយនៅក្រោយពេលអ្នកជំនាញបានចេញសេចក្ដីសន្និដ្ឋាន

[41] មាត្រា ១៤២ សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី

[42] មាត្រា ១៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

នោះភាគីអាចប្តឹងផាត់ចោលអ្នកជំនាញនោះបាន[43]។

តុលាការអាចឱ្យអ្នកជំនាញកោសលវិច័យ បញ្ចេញយោបល់ជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន។ ហើយក្នុងករណីដែលមានការចាំបាច់សម្រាប់កិច្ចការធ្វើកោសលវិច័យ អ្នកជំនាញខាងកោសលវិច័យអាចចូលរួមក្នុងសវនាការ ហើយអាចស្នើសុំឱ្យតុលាការធ្វើការ សាកសួរសាក្សី ឬ សាមីភាគី ឬដោយទទួលការអនុញ្ញាតពីតុលាការ និងសាកសួរដោយផ្ទាល់ទៅលើជនទាំងនោះបាន[44]។

ការធ្វើសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ច្បាប់អាចចាត់ទុកជាប្រភេទនៃភស្តុតាងមួយ ដោយហេតុថា មតិយោបល់ ឬការអះអាងរបស់អ្នកជំនាញក្រោយពីបានធ្វើការរកឃើញនូវរបកគំហើញនានា អំពីខណៈនៃបញ្ហាចោទជាបច្ចេកទេសទាំងនោះ[45]។

ចំពោះជនដែលពុំអាចធ្វើជាអ្នកជំនាញខាងកោសលវិច័យបាន ក្នុងករណីដូចខាងក្រោម៖

ក-ការធ្វើកោសលវិច័យនោះ បណ្តាលឱ្យអ្នកជំនាញផ្ទាល់ខ្លួន ឬសហព័ទ្ធ ឬញាតិឯទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬទទួលការផ្តន្ទាទោស។ ហើយចំពោះការកោសលវិច័យនោះ អាចធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលបានរៀបរាប់ខាងលើនេះឬបណ្តាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

ខ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់ខ្លួន ជាមន្ត្រីរាជការ ឬអតីតមន្ត្រីរាជការ។

គ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មប គិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុងសាសនា ឬអ្នកដែលធ្លាប់មានមុខងារខាងលើនេះក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលត្រូវលាក់ការសម្ងាត់។

ឃ-ចំណុចដែលត្រូវធ្វើកោសលវិច័យនោះ មានការពាក់ព័ន្ធនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬ វិជ្ជាជីវៈ[46]។

### **១.២.៤. ភស្តុតាងជាឯកសារ**

ឯកសារ គឺជាវត្ថុរូបី (ក្រដាស-ឈើ) ដែលបង្ហាញឱ្យឃើញនូវឆន្ទៈជាកំណត់របស់បុគ្គលណាមួយ ដោយអក្សរ ឬសញ្ញាផ្សេងៗ។ វត្ថុផ្សេងទៀតដែលមិនមែនជាឯកសារ ដូចជា ប្លង់រូបថត ខ្សែអាត់

[43] មាត្រា ១៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[44] មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[45] សៀវភៅនីតិភស្តុតាង របស់លោក អ៊ិន បូផា

[46] មាត្រា ១៩៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

ខ្សែវីដេអូ ឬវត្ថុផ្សេងទៀតដែលបង្កើតឡើងសម្រាប់ផ្តល់ព័ត៌មាន ក៏ត្រូវបានចាត់ទុកជាឯកសារផងដែរ។

ភស្តុតាងជាឯកសារ គឺជាឧបករណ៍តាមផ្លូវច្បាប់ដែលអាចបញ្ជាក់អំពីសារៈសំខាន់ក្នុងការទាមទារ។ ប៉ុន្តែដើម្បីទទួលស្គាល់ថា ឯកសារណាមួយមានសមត្ថភាព និងអំណាចជាទម្រង់នៃភស្តុតាងទាល់តែឯកសារនោះ ជាឯកសារដែលត្រូវបង្កើតឡើងត្រឹមត្រូវ[47]។ ឧទាហរណ៍៖ លិខិតកិច្ចសន្យាមួយដែលបង្កើតឡើងដោយឈ្មោះ "X" ក្នុងរឿងខ្ចីប្រាក់ ដែលសរសេរថា ឈ្មោះ "X" បានខ្ចីប្រាក់ចំនួន ១.០០០.០០០ (មួយលាន)រៀល ពុំមានអានុភាពជាភស្តុតាង ដើម្បីបញ្ជាក់អង្គហេតុខ្ចីប្រាក់រវាងឈ្មោះ "A" និងឈ្មោះ "B" បានទេ។

ការពិនិត្យភស្តុតាងជាឯកសារ គឺជាប្រភេទភស្តុតាងដែលមានសារៈសំខាន់ ហើយនិងជាមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីបញ្ជាក់ពីអង្គហេតុ។ ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់នូវឯកសារដែលសាមីភាគីមាន ឬដោយដាក់ពាក្យសុំទៅតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក[48]។ ហើយចំពោះការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារដែលសរសេរជាភាសាបរទេស ភាគីដែលស្នើសុំត្រូវភ្ជាប់មកជាមួយនូវសេចក្តីបកប្រែត្រង់ចំណុចដែលខ្លួនសុំឱ្យពិនិត្យ។ ក្នុងករណីដែលភាគីម្ខាងទៀត មានយោបល់អំពីភាពត្រឹមត្រូវនៃសេចក្តីបកប្រែដែលបានដាក់ឱ្យតុលាការពិនិត្យនោះ ភាគីនោះត្រូវដាក់ជូនតុលាការនូវយោបល់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ។ ហើយប្រសិនបើភាគីស្នើសុំតុលាការធ្វើការពិនិត្យភស្តុតាងជាឯកសារ ប៉ុន្តែឯកសារនោះមិនត្រូវបានម្ចាស់ឯកសារដាក់ជូន ឬផ្ញើជូនតុលាការពិនិត្យទេនោះ ភាគីស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារនោះ អាចស្នើសុំឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារបាន តាមពាក្យសុំដែលធ្វើឡើងជាលាយល័ក្ខណ៍អក្សរដោយបញ្ជាក់ឱ្យបានច្បាស់លាស់នូវចំណុចដូចខាងក្រោម៖

ក-ចំណងជើង និងខ្លឹមសារឯកសារ។

ខ-ម្ចាស់ឯកសារ។

គ-អង្គហេតុដែលត្រូវបញ្ជាក់បំភ្លឺ។

ភស្តុតាងជាឯកសារនេះត្រូវបានគេបែងចែកជាពីរ គឺ ឯកសារសាធារណៈ និងឯកសារឯកជន ដើម្បីមានភាពងាយស្រួលក្នុងការវាយតម្លៃ និងសម្រេចសេចក្តីរបស់ចៅក្រម។

**ក. ឯកសារសាធារណៈ**

ឯកសារសាធារណៈ គឺជាឯកសារដែលត្រូវបានធ្វើឡើងដោយមន្ត្រីរាជការក្នុងការបំពេញមុខ

[47] សៀវភៅមេរៀន ស្តីពីក្រមរដ្ឋប្បវេណី និងសង្ខេប នីតិវិធីរដ្ឋប្បវេណី របស់លោក សៀង មុន្នីរ័ត្ន ជាសិស្សចៅក្រមជំនាន់៣

[48] មាត្រា ១៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

នាទីរបស់ខ្លួន ដោយផ្អែកលើសិទ្ធិអំណាចរបស់ខ្លួន។ ឧទាហរណ៍ដូចជា មូលសាលក្រម, កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់, ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃបញ្ជីអត្រានុកូលដ្ឋាន, ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីដីធ្លី ជាអាទិ៍។ ហើយចំពោះឯកសារសាធារណៈ បើទទួលស្គាល់ថា ឯកសារនេះត្រូវបានធ្វើឡើងដោយមន្ត្រីរាជការនៅក្នុងមុខនាទីដោយផ្អែកលើទម្រង់ និងខ្លឹមសារនៃឯកសារ នោះត្រូវសន្មត់ថាជាឯកសារសាធារណៈ ដែលបានធ្វើឡើងដោយត្រឹមត្រូវ។ ប្រសិនបើមានមន្ទិលសង្ស័យទៅលើភាពត្រឹមត្រូវក្នុងការធ្វើឯកសារសាធារណៈ នោះតុលាការអាចសួរ ដោយឆន្ទានុសិទ្ធិទៅក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធបាន។ លើសពីនេះ ចំពោះឯកសារដែលត្រូវបានទទួលស្គាល់ ត្រូវបានធ្វើឡើងដោយក្រសួង ឬស្ថាប័នបរទេស ក៏ត្រូវបានសន្មតថាជាឯកសារសាធារណៈផងដែរ[49]។

**ខ.ឯកសារឯកជន**

លិខិតឯកជន គឺជាឯកសារដែលត្រូវបានបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ[50]។ ចំពោះឯកសារឯកជន គឺជាឯកសារដែលមានចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ឬអ្នកតំណាងត្រូវសន្មត់ថា ជាឯកសារដែលបានធ្វើឡើងដោយត្រឹមត្រូវ (ឧទាហរណ៍ លិខិតកិច្ចសន្យា, លិខិតបណ្តាំមតកសាសន៍, លិខិតធ្វើប្រទានកម្ម ជាអាទិ៍)។ ឯកសារឯកជន ចាំបាច់ត្រូវតែធ្វើការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្កើតឯកសារនោះ។ ដូចនេះចំពោះភាគីម្ខាងទៀត ដែលធ្វើការតវ៉ាអំពីភាពមិនត្រឹមត្រូវនៃការបង្កើតឯកសារឯកជនបែបនេះ ភាគីនោះចាំបាច់ត្រូវតែធ្វើការបញ្ជាក់ថាឯកសារនោះត្រូវបានបង្កើតឡើង ដោយខុសពីឆន្ទៈរបស់អ្នកដែលបានធ្វើឯកសារ[51]។

**គ.ការផ្តល់ឯកសារ**

ភស្តុតាងជាឯកសារ មានសារៈសំខាន់ណាស់សម្រាប់ភាគីនៅក្នុងរឿងក្តី ដូចនេះភាគីត្រូវមានករណីយកិច្ចផ្តល់ឯកសារទៅតុលាការដើម្បីជាផលប្រយោជន៍របស់ខ្លួន។ មួយវិញទៀតប្រសិនបើឯកសារនោះមិនស្ថិតនៅក្នុងដៃរបស់គូភាគីនោះ ភាគីដែលស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងជាឯកសារដែលត្រូវដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យបុគ្គលដែលជាម្ចាស់ឯកសារត្រូវផ្តល់ជូននូវឯកសារនោះទៅតុលាការ ហើយករណីយកិច្ចក្នុងការផ្តល់ឯកសារនេះ បុគ្គលដែលជាម្ចាស់ឯកសារពុំអាចបដិសេធនូវការផ្តល់ឯកសារបានឡើយ។ ប៉ុន្តែប្រសិនបើឯកសារនោះត្រូវនឹងចំណុចដូចខាង

[49] មាត្រា ១៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[50] សន្ទានុក្រម នៃក្រមរដ្ឋប្បវេណី

[51] សេចក្តីពន្យល់ក្រមអំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១

ក្រោមនេះ បុគ្គលដែលជាម្ចាស់ឯកសារអាចធ្វើការបដិសេធនូវការផ្ដល់ឯកសារនេះបាន ដោយចំណុចទាំងនោះមានដូចជា៖

ក-ឯកសារមានសរសេរអំពីហេតុដែលបណ្ដាលឱ្យម្ចាស់ឯកសារ ឬសហព័ទ្ធ ឬញាតិដទៃទៀតរបស់ខ្លួន អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬទទួលការផ្ដន្ទាទោស ឬហេតុដែលអាចនឹងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដែលរៀបរាប់ខាងលើ ឬអាចបណ្ដាលឱ្យមានការបែកបាក់ធ្ងន់ធ្ងរដល់ទំនាក់ទំនងគ្រួសារ។

ខ-ឯកសារមានការពាក់ព័ន្ធទៅនឹងកិច្ចការសម្ងាត់ក្នុងមុខនាទីរបស់មន្ត្រីរាជការ ហើយផ្ដល់ឯកសារនោះ អាចបណ្ដាលឱ្យមានឧបសគ្គធ្ងន់ធ្ងរក្នុងការបំពេញការងាររដ្ឋ។

គ-ឯកសារមានសរសេរអំពីអង្គហេតុដែលបានដឹងដោយវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឆ្មបគិលានុបដ្ឋាយិកា គិលានុបដ្ឋាក ឱសថការី មេធាវី អ្នកមានមុខងារក្នុសាសនា ឬអ្នកដែលធ្លាប់មានមុខងារខាងលើនេះនៅក្នុងការបំពេញតួនាទីរបស់ខ្លួន ហើយដែលខ្លួនមិនបានទទួលការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់ ឬហេតុដែលពាក់ព័ន្ធទៅនឹងការសម្ងាត់ក្នុងបច្ចេកទេស ឬវិជ្ជាជីវៈ ហើយដែលខ្លួនមិនបានទទួលបានការលើកលែងពីករណីយកិច្ចលាក់ការសម្ងាត់[52]។

ប្រសិនបើបុគ្គលដែលជាម្ចាស់ឯកសារមិនធ្វើការផ្ដល់នូវឯកសារតាមដីកាបង្គាប់ឱ្យផ្ដល់ឯកសាររបស់តុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចធ្វើការពិន័យជាប្រាក់ចំនួនមិនលើសពី ២.០០០.០០០ (ពីរលាន)រៀល ដោយដីកាសម្រេច។ ដីកាសម្រេចអំពីការពិន័យជាប្រាក់នេះអាចធ្វើការប្ដឹងជំទាស់បាន[53]។

### ១.២.៥.ការត្រួតពិនិត្យ

ការត្រួតពិនិត្យ គឺជាប្រភេទមួយនៃការពិនិត្យភស្តុតាង ដែលជាការពិនិត្យផ្ទាល់ទៅលើលក្ខណៈធាតុរបស់វត្ថុ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យដោយវិញ្ញាណទាំង៥ របស់ចៅក្រម (ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ) ហើយយកអត្ថន័យអំពីលទ្ធផលនៃការពិនិត្យនោះមកធ្វើជាភស្តុតាង។ ទោះជាឯកសារក៏ដោយ បញ្ហាមិនស្ថិតនៅលើអត្ថន័យ ដែលសរសេរនៅលើឯកសារនោះទេ ប្រសិនបើជាវិធីស្រាវជ្រាវភស្តុតាងលើលក្ខណៈនៃក្រដាស ឬអក្សរសរសេរដែឯកសារនោះគឺជាកម្មវត្ថុនៃការត្រួតពិនិត្យ។ ចំពោះរូបបុគ្គល ក្នុងករណីដែលមានបញ្ហាលើអត្ថន័យ នៃសេចក្ដីសំអាង យើងធ្វើដោយវិធីសាកសួរសាក្សី ឬសាកសួរសាមីភាគី តែបើជាបញ្ហាលើរូបរាងកាយ ឬ

[52] មាត្រា ១៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[53] មាត្រា ១៦២ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

លើភិនភាគវិញ គឺជាកម្មវត្ថុនៃការពិនិត្យ[54]។ ការត្រួតពិនិត្យមិនមែនជាការពិនិត្យទៅលើខ្លឹមសារដែលមាននៅក្នុងវត្ថុណាមួយនោះទេ ពោលគឺជាការពិនិត្យទៅលើលក្ខណៈធាតុ បាតុភូតនៃឯកសារដូចជាការពិនិត្យទៅលើលក្ខណៈប្រភេទនៃក្រដាសដែលបានកត់ត្រា ឬសរសេរ ឬលក្ខណៈនៃអក្សរតែពុំមែនជាខ្លឹមសារនៃការសរសេរឡើយ។

## ផ្នែកទី២ ការថែរក្សាការពារភស្តុតាង

### ២.១. នីតិវិធីថែរក្សាការពារភស្តុតាង

ការថែរក្សាការពារភស្តុតាង ត្រូវបានធ្វើឡើងតាមពាក្យសុំរបស់ភាគី នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់។ ប៉ុន្តែនៅក្នុងករណីពិសេសខ្លះ ដែលអាចធ្វើការពិនិត្យភស្តុតាង មុនពេលដាក់ពាក្យបណ្តឹងបាន ក្នុងគោលដៅថែរក្សាការពារភស្តុតាងដែលអាចនឹងបាត់បង់ ឬកែក្រឡៃបាន ដូចជាការសាកសួរសាក្សីដែលស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដល់ជីវិត ឯកសារតាមដានការព្យាបាលអ្នកជំងឺជាអាទិ៍។ ចំពោះពាក្យសុំឱ្យថែរក្សាការពារភស្តុតាង ដែលធ្វើក្រោយពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅតុលាការនៃលំដាប់ថ្នាក់ដែលភស្តុតាងនោះនឹងត្រូវបានប្រើប្រាស់។ ហើយប្រសិនបើពាក្យសុំនោះត្រូវបានធ្វើមុនពេលដាក់ពាក្យបណ្តឹង ត្រូវធ្វើនៅសាលាដំបូងដែលមានសមត្ថកិច្ច នៅទីសំណាក់របស់បុគ្គលដែលត្រូវទទួលការសាកសួរ ឬរបស់បុគ្គលដែលជាម្ចាស់ឯកសារ ឬនៅទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ។ ប្រសិនបើក្នុងស្ថានភាពបន្ទាន់ ទោះជានៅក្រោយការដាក់ពាក្យបណ្តឹងក៏ដោយ ក៏ពាក្យសុំថែរក្សាការពារភស្តុតាង អាចធ្វើបានដែរ នៅសាលាដំបូងដែលមានសមត្ថកិច្ចលើទីសំណាក់របស់បុគ្គលដែលត្រូវទទួលការសាកសួរ ឬរបស់បុគ្គលដែលជាម្ចាស់ឯកសារ ឬលើទីកន្លែងនៃវត្ថុដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ[55]។

ភាគីដែលបានដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យថែរក្សាការពារភស្តុតាង ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវសរសេរនូវចំណុចមួយចំនួនដូចខាងក្រោម៖

ក-ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគីម្ខាងទៀត។

ខ-អង្គហេតុដែលត្រូវបញ្ជាក់។

គ-ភស្តុតាងដែលត្រូវថែរក្សាការពារ។

ឃ-មូលហេតុនៃការថែរក្សាការពារភស្តុតាង។ មូលហេតុនៃការថែរក្សាការពារភស្តុតាង ត្រូវធ្វើសេចក្តីបញ្ជាក់ជំបូង[56]។

[54] មាត្រា ១៦១ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី
[55] មាត្រា ១៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦
[56] មាត្រា ១៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

ប្រសិនបើពាក្យសុំឱ្យតុលាការថែរក្សាការពារភស្តុតាង ត្រូវបានលើកចោលភាគីអាចធ្វើការប្ដឹងជំទាស់បាន[57]។

នីតិវិធីនៃការថែរក្សាការពារភស្តុតាងអាចចាប់ផ្ដើមមុនពេលដាក់ពាក្យបណ្ដឹងក៏បាន ឬក្រោយពេលដាក់ពាក្យបណ្ដឹងក៏បាន ប៉ុន្តែត្រូវមុនពេលដល់ដំណាក់កាលនៃការពិនិត្យភស្តុតាង។ ជាគោលការណ៍ នីតិវិធីនេះត្រូវចាប់ផ្ដើមតាមពាក្យសុំរបស់ភាគី ប៉ុន្តែក្រោយពេលមានពាក្យបណ្ដឹងប្រសិនបើយល់ឃើញថាមានការចាំបាច់ តុលាការអាចចាប់ផ្ដើមដោយឆន្ទានុសិទ្ធិ[58]។

**២.២.លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារ**

លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារនេះ មានអានុភាពជាភស្តុតាង នៅក្នុងបណ្ដឹងអង្គសេចក្ដី។ ប៉ុន្តែភាគីត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីលទ្ធផលនៃការពិនិត្យភស្តុតាងនោះនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្ដឹងអង្គសេចក្ដី[59]។ នេះគឺដើម្បីបង្ហាញលទ្ធផលនៃការពិនិត្យភស្តុតាង ដែលបានធ្វើជាមូលដ្ឋាននៃសាលក្រមដោយចាត់ទុកថា មានអានុភាពដូចគ្នានឹងសកម្មភាពដែលបានធ្វើឡើងនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ដែរ។ ពេលចាប់ផ្ដើមចាត់ការបណ្ដឹងអង្គសេចក្ដី តុលាការដែលបានធ្វើការពិនិត្យភស្តុតាង ត្រូវផ្ញើកំណត់ហេតុស្ដីពីការពិនិត្យភស្តុតាងទៅតុលាការនៃបណ្ដឹងអង្គសេចក្ដី។ លទ្ធផលនៃការពិនិត្យភស្តុតាងដែលត្រូវបានថែរក្សាការពារ នៅតែមានអានុភាពទោះជាក្រោយពេលនោះអាចធ្វើការពិនិត្យភស្តុតាងនោះនៅក្នុងបណ្ដឹងអង្គសេចក្ដីក៏ដោយ ក៏ប៉ុន្តែក្នុងករណីដែលបានធ្វើការសាកសួរសាក្សីនៅក្នុងនីតិវិធីនៃការថែរក្សាការពារភស្តុតាង ប្រសិនបើមានការស្នើសុំពីភាគីតុលាការត្រូវធ្វើការសាកសួរសាក្សីម្ដងទៀតនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។ ចំពោះសោហ៊ុយនៃការថែរក្សាការពារភស្តុតាង គឺជាមួយភាគនៃប្រាក់ប្រដាប់ក្ដីនៃបណ្ដឹងអង្គសេចក្ដី[60]។

ឲឲ✶ឲឲ

[57] មាត្រា ១៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[58] មាត្រា ១៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

[59] មាត្រា ១៦៣ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

[60] សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវ នឹងចងក្រងបានជាអត្ថបទសារណាមួយនេះ យើងអាចយល់យ៉ាងច្បាស់អំពីអត្ថន័យនៃភស្តុតាង ការបែងចែកប្រភេទនៃភស្តុតាង និងនីតិវិធីរបស់តុលាការក្នុងការពិនិត្យភស្តុតាងក្នុងរឿងក្តីរដ្ឋប្បវេណី។ ភស្តុតាងនៅក្នុងរឿងក្តីរដ្ឋប្បវេណី គឺគូភាគីមានករណីយកិច្ចដាក់ជូនតុលាការដើម្បីធ្វើការពិនិត្យ ហើយជាពិសេសចំពោះភាគីដែលបានធ្វើការដាក់ពាក្យបណ្តឹងដើម្បីទាមទារ គឺមានភាពចាំបាច់ណាស់ ក្នុងដាក់ភស្តុតាងជូនតុលាការ ដើម្បីជាការបញ្ជាក់ពីមូលដ្ឋានក្នុងការទាមទាររបស់ខ្លួន។ ក្នុងនេះផងដែរ តុលាការត្រូវធ្វើការសម្រេចសេចក្តី ដោយផ្អែកទៅភស្តុតាងដែលភាគីបានធ្វើការដាក់ជូនតុលាការដើម្បីពិនិត្យ ប៉ុន្តែប្រសិនភស្តុតាងរបស់ភាគីម្ខាងទៀតមានភាពច្បាស់លាស់ជាង ឬអាចបញ្ជាក់អំពីនត្ថិភាពនៃអង្គហេតុក្នុងការទាមទាររបស់ភាគីនោះ តុលាការនឹងធ្វើការពិចារណាចំពោះការទាមទារនោះ។ ភស្តុតាង គឺជាឯកសារមួយដ៏សំខាន់ដែលសម្រាប់បញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុណាមួយដែលភាគីបានធ្វើការអះអាងនៅចំពោះមុខតុលាការ ដោយផ្អែកលើគោលការណ៍សម្រេចសេចក្តីដោយភស្តុតាង។ បើទោះបីជា មានភស្តុតាងដើម្បីបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុក៏ពិតមែន តុលាការនៅតែឈរលើគោលការណ៍ជំនឿទុកចិត្តដោយសេរី។ ចំពោះភស្តុតាងដែលភាគីបានធ្វើការដាក់ជូនតុលាការដើម្បីពិនិត្យទាំងអស់ពុំមានអនុភាពចងតុលាការនោះទេ។

ចំពោះនីតិវិធីនៃការពិនិត្យភស្តុតាងត្រូវបានធ្វើឡើងដោយ ផ្អែកលើគោលការណ៍ចំពោះមុខដាក់ស្តែងការពិនិត្យភស្តុតាងត្រូវបានធ្វើឡើងចំពោះមុខគូភាគី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធានាឱ្យបាននូវតម្លាភាពចំពោះមុខច្បាប់ និងធានាឱ្យបាននូវភាពយុត្តិធម៌ចំពោះការវិនិច្ឆ័យសេចក្តីរបស់ចៅក្រម។ តុលាការក៏អាចពិនិត្យភស្តុតាងនៅមុននីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានផងដែរ។ មួយវិញទៀតការពិនិត្យភស្តុតាងត្រូវធ្វើឡើងតាមពាក្យសុំរបស់ភាគី ដែលភាគីមានកាតព្វកិច្ចកំណត់អំពីប្រភេទនៃភស្តុតាងដែលត្រូវដាក់ជូនតុលាការធ្វើពិនិត្យឱ្យបានច្បាស់លាស់។

ដូចនេះ ភស្តុតាង គឺជាកាតាលីករដ៏សំខាន់ក្នុងការស្វែងរកយុត្តិធម៌ចំពោះគូភាគីនៅក្នុងនីតិវិធីនៃបណ្តឹង ហើយជាមូលដ្ឋានចាំបាច់ណាស់ ដែលតុលាការតែងតែធ្វើការពិចារណាទៅលើភស្តុតាងដែលគូភាគីបានដាក់ដើម្បីបង្ហាញជូនតុលាការ ដើម្បីធ្វើការវិនិច្ឆ័យសេចក្តីទៅលើអង្គហេតុ ថាភស្តុតាងដែលគូភាគីបានធ្វើការដាក់ជូនតុលាការនោះមានភាពត្រឹមត្រូវ ឬយ៉ាងណា។ តុលាការមានតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចសេចក្តីដល់ភាគីដែលមានវិវាទ ដោយភាគីទាំងនោះបានធ្វើការជឿជាក់យ៉ាងមុតមាំថា តុលាការនឹងធ្វើការសម្រេចសេចក្តីដោយភាពយុត្តិធម៌ចំពោះពួកគេ។

៧៧✶៦៦

# ឯកសារយោង

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ខ. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

គ. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

## ២.សៀវភៅ

ក. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

ខ. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១៖ នីតិវិធីនៃបណ្តឹង ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

គ. សៀវភៅមេរៀន ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ៣ សមិទ្ធផលគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ របស់ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី១ ខែមីនា ឆ្នាំ២០១៧

ឃ.សៀវភៅនីតិភស្តុតាង របស់អនុបណ្ឌិតនីតិសាស្ត្រ អ៊ុន បូជា បោះពុម្ពលើកទី២ ឆ្នាំ២០១៦

ង. សៀវភៅមេរៀន ក្រមរដ្ឋប្បវេណី និងសង្ខេបនីតិវិធីរដ្ឋប្បវេណី របស់ លោក សឿន មុនីរ័ត្ន សិស្សចៅក្រមជំនាន់៣

ច. វចនានុក្រម សម្តេចព្រះសង្ឃរាជ ជោត្តញាណោ ជួន ណាត ឆ្នាំ ១៩៦៧

# ឧបសម្ព័ន្ធ

| បញ្ជីរាយនាមលិខិតឧបសម្ព័ន្ធ | | |
|---|---|---|
| ល.រ | នាមលិខិត | ទំព័រ |
| ១ | ពាក្យបណ្តឹងលែងលះ | ២ |
| ២ | សេចក្តីបញ្ជាក់ដំបូងក្នុងរឿងរក្សាការពារ | ២ |
| ៣ | ដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម | ១ |
| ៤ | ពាក្យសុំបញ្ចូលភស្តុតាងជាសាក្សី | ១ |
| ៥ | ពាក្យស្នើសឱ្យពិនិត្យភស្តុតាងជាសាក្សី | ១ |
| ៦ | ដីកាកោះ | ២ |
| ៧ | ឧបសព័ន្ធ(នីតិវិធីក្នុងការធ្វើសម្បថ) | ២ |
| ៨ | ពាក្យសុំបញ្ចូលភស្តុតាងជាឯកសារ | ១ |
| ៩ | ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ | ១ |
| ១០ | ពាក្យស្នើសុំថែរក្សាការពារភស្តុតាង | ១ |
| ១១ | ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង | ១ |
| ១២ | ដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាង | ១ |
| ១៣ | ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង | ១ |
| ១៤ | ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង | ១ |
| | សរុប | ១៨ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យបណ្ដឹងលែងលះ</u>

**ដើមចោទ**ៈឈ្មោះ................ភេទ.......អាយុ........ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ.................មានអាសយដ្ឋាននៅផ្ទះលេខៈ...... ផ្លូវ.......... ក្រុម......... សង្កាត់................ ខណ្ឌ..រាជធានីភ្នំពេញ(*សូមទំនាក់ទំនងទូរស័ព្ទលេខ* ...............................
**ចុងចម្លើយ** ឈ្មោះ...................ភេទ.........អាយុ.......ឆ្នាំ មុខរបរ........... មានសញ្ជាតិខ្មែរមានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខៈ..........ផ្លូវ............. ក្រុម.......... សង្កាត់....................... ខណ្ឌ...................រាជធានីភ្នំពេញ ។

**<u>សូមគោរពចូលមក</u>**
**លោកប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

<u>*សូមមេត្តាជ្រាប*</u> ។

**កម្មវត្ថុៈ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញសាលក្រមៈ**

១-.........................................................................................................................................
២-.........................................................................................................................................
៣-.........................................................................................................................................
៤-.........................................................................................................................................

**យោងៈ**-.........................................................................................................................................។
-.........................................................................................................................................
-.........................................................................................................................................

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមគោរពជម្រាបជូន**លោកប្រធាន**មេត្តាជ្រាបថាៈ ខ្លឹមសារនៃសាលក្រមដើមចោទទាមទារ, អង្គហេតុចាំបាច់ និងអង្គហេតុហេតុជាមូលហេតុចម្បង និងភស្តុតាង ដើម្បីបញ្ជាក់អំពីការទាមទារដូចខាងក្រោមៈ

**១.អង្គហេតុចាំបាច់បញ្ជាក់ការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ**

.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................

**២.ភស្តុតាងបញ្ជាក់ការទាមទារ**

.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................
.........................................................................................................................................

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តា ពិនិត្យ និងសម្រេចដូចមានចែងក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០.......

**ស្នាមមេដៃស្តាំ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សេចក្ដីបញ្ជាក់ដំបូង</u>

មេធាវី...................................អត្តលេខ................ ទូរស័ព្ទលេខ ....................................ជាមេធាវី**ក្រុមមេធាវី**....................................................មានការិយាល័យនៅអគារលេខ............ ជាន់ទី........... ផ្លូវលេខ....... សង្កាត់.............. ខណ្ឌ............... រាជធានីភ្នំពេញ និងជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ...........................។

## <u>សូមគោរពជូន</u>

## ប្រធានសាលាដំបូងរាជធានី/ខេត្ត....................................

**កម្មវត្ថុ៖** សំណើសុំដាក់ជូនសេចក្ដីបញ្ជាក់ដំបូងបន្ថែមអំពីទ្រព្យសម្បត្តិដែលត្រូវរក្សាការពារ។

**យោង៖** ពាក្យស្នើសុំដីកាសម្រេចចាត់ចែងរក្សាការពារ ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១៨។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកស្រី** មេត្តាជ្រាបអំពីសេចក្ដីបញ្ជាក់ដំបូង អំពីទ្រព្យសម្បត្តិដែលនឹងត្រូវរក្សាការពារ គឺជាទ្រព្យសម្បត្តិរបស់កូនបំណុលឈ្មោះ ...........................ដូចខាងក្រោម៖

### ១. សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវរក្សាការពារ

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

### ២. ភាពចាំបាច់ដែលត្រូវរក្សាការពារ

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តា ពិនិត្យ និងសម្រេចដូចមានចែងក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០.......

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**

លេខ..................បប

**ដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម**

យើង ជាចៅក្រមសាលាដំបូងខេត្ត ទទួលបន្ទុកចាត់ការពាក្យបណ្ដឹងអង្គសេចក្ដី លេខ........... ចុះថ្ងៃទី.......ខែ...........ឆ្នាំ២០០.....។

បានឃើញបទប្បញ្ញត្តិមាត្រា១០១.១០២ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦។

**យល់ឃើញថា**ដើម្បីងាយស្រួល និងមានភាពច្បាស់លាស់ ក្នុងកិច្ចធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលដែលនឹងប្រព្រឹត្តទៅនៅកាលបរិច្ឆេទថ្ងៃទី.........ខែ...........ឆ្នាំ២០០......វេលាម៉ោង............................

**បង្គាប់មក**

១/ឈ្មោះ..................................................................................................................

ជាភាគី..............................ឱ្យដាក់នូវឯកសារត្រៀមសម្រាប់ធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលសម្រាប់ កាលបរិច្ឆេទខាងលើក្នុងអំឡុងពេល០៧( ប្រាំពីរ ) ថ្ងៃគិតចាប់ពីថ្ងៃឈ្មោះ..................................................បានទទួលដីកាបង្គាប់នេះ។

២/ក្នុងឯកសារត្រៀមសម្រាប់ធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលសម្រាប់កាលបរិច្ឆេទខាងលើ ភាគី ត្រូវសរសេរនូវខ្លឹមសារដូចក្នុងបទប្បញ្ញត្តិមាត្រា១០១ កថាខណ្ឌ២.៣ និងមាត្រា១០២ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦។

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

**ចៅក្រម**

បានទទួល

ថ្ងៃទី......ខែ..........ឆ្នាំ.២០០....

ភាគី........................

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំបញ្ចូលឥស្សុតាង

ខ្ញុំបាទឈ្មោះ................................ ភេទ.............. ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខៈ............ សង្កាត់/ឃុំ ..................... ខណ្ឌ/ស្រុក ..................... រាជធានី/ខេត្ត.................................

## សូមគោរពជូន

**លោកចៅក្រមនៃសាលាដំបូងរាជធានី/ខេត្ត**..............................

*សូមទានជ្រាប។*

**កម្មវត្ថុ៖** សំណើសុំដាក់បញ្ចូលកស្តុតាងជាសាក្សីឈ្មោះ.........................នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ...........ចុះថ្ងៃទី........ ខែ.......... ឆ្នាំ..................... របស់សាលាដំបូង..............................

**យោង ៖** -សំណុំរឿងរដ្ឋប្បវេណីលេខៈ ............ ចុះថ្ងៃទី.......ខែ....ឆ្នាំ....របស់សាលាដំបូងរាជធានី/ខេត្ត........។

-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

-..............................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទមានកិត្តិយសសូមគោរពជូន**លោកចៅក្រម** មេត្តា ជ្រាបថា៖

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

......................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកចៅក្រម** មេត្តាសម្រេចទទួលនូវកស្តុតាងដូចដែលមាននៅក្នុងកម្មវត្ថុខាងលើដោយក្តីមេត្តាអនុគ្រោះបំផុត។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី......... ខែ......... ឆ្នាំ២០១៨

**ស្នាមមេដៃស្តាំ**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំឱ្យពិនិត្យភស្តុតាង

ខ្ញុំបាទឈ្មោះ........................ ភេទ........... ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ផ្លូវលេខ ............. សង្កាត់/ឃុំ ..................... ខណ្ឌ/ស្រុក ..................... រាជធានី/ខេត្ត....................................។

## សូមគោរពជូន

### លោកចៅក្រមនៃសាលាដំបូងរាជធានី/ខេត្ត.............................

*សូមទានជ្រាប។*

**កម្មវត្ថុ៖** ស្នើសុំឱ្យតុលាការធ្វើការពិនិត្យភស្តុតាងជាសាក្សី ឈ្មោះ ........................... ដែលអាចបម្លៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ...............ចុះថ្ងៃទី........ ខែ.......... ឆ្នាំ..................... របស់សាលាដំបូង ...............................................។

**យោង** ៖ -សំណុំរឿងរដ្ឋប្បវេណីលេខៈ ............ ចុះថ្ងៃទី........... ខែ......... ឆ្នាំ.......... របស់សាលាដំបូងរាជធានី/ខេត្ត.

-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

-.....................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទមានកិត្តិយសសូមគោរពជូន**លោកចៅក្រម** មេត្តា ជ្រាបថា៖

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.........................................................................................................................................

.......................................................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកចៅក្រម** មេត្រាពិនិត្យនូវភស្តុតាង ដូចដែល មាននៅក្នុងកម្មវត្ថុខាងលើដោយក្តីមេត្តាអនុគ្រោះបំផុត។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី........ ខែ........ ឆ្នាំ២០១៨

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាកោះ

| | |
|---|---|
| ជូនចំពោះឈ្មោះ ................ភេទប្រុស អាយុ.......ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកអង្គការ មានទីលំនៅបច្ចុប្បន្ននៅ ផ្ទះលេខ៩០ ផ្លូវលេខ២៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ( ទូរស័ព្ទលេខ ០១២ --- ---) | |
| សញ្ញាណនៃរឿងក្តី និង ភាគី (កម្មវត្ថុបណ្តឹង) | សំណុំរឿងរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី......... ខែ....... ឆ្នាំ...........។<br>-ដើមចោទឈ្មោះ ...........ភេទស្រី អាយុ ឆ្នាំ ។<br>-មានលោក/លោកស្រី ..........................ជាមេធាវីតំណាងដោយអាណត្តិ ។<br>-ចុងចម្លើយឈ្មោះ ............ ភេទប្រុស អាយុ ៣៤ឆ្នាំ ។<br>-មានលោក/លោកស្រី ..........................ជាមេធាវីតំណាងដោយអាណត្តិ។ |
| កាលបរិច្ឆេទ និង ទីកន្លែង ដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី........... ខែ................ ឆ្នាំ២០១៨ វេលាម៉ោង..........................................<br>នៅសាលាដំបូងរាជធានីភ្នំពេញ (**បន្ទប់ "....." ជាន់ទី........**) |
| ដំណាក់កាលនៃនីតិវិធី (សូមគូសលើនៃនីតិវិធីដែលចាំបាច់) | ១.ការទាញហេតុផលដោយផ្ទាល់មាត់□ ២.ការប្រកាសសាលក្រម□ ៣.ការផ្សះផ្សា□ ៤.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល□ ៥.ការសាកសួរសាក្សី□ ៦.ការសាកសួរសាមីភាគី□ ៧.ការសាកសួរអ្នកធ្វើកោសលវិច័យ□ ៨.ការត្រួតពិនិត្យ□ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ (សូមសរសេរបញ្ជាក់ ពីឈ្មោះឯកសារ បើចាំបាច់ ឱ្យកាន់មក) | |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១.ចំពោះសាមីភាគី តុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចរបស់ភាគី ម្ខាងទៀតថាការពិតបាន។<br>២.ចំពោះសាក្សី តុលាការអាចបង្គាប់ឱ្យនាំខ្លួន ឬពិន័យជាប្រាក់ចំនួនមិនលើស ពី ១.០០០.០០០ រៀល។<br>៣.ចំពោះអ្នកធ្វើកោសលវិច័យ តុលាការអាចពិន័យជាប្រាក់មិនលើសពី ១.០០០.០០ ល។ |
| សូមបង្ហាញខ្លួនឱ្យទាន់ពេលវេលា និងទីកន្លែង ដូចដែលកំណត់ខាងលើនេះ។<br>ថ្ងៃ..................................... ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១<br>រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ............ ឆ្នាំ២០១៨<br>**ចៅក្រម**<br>អ្នកទទួល<br>ថ្ងៃទី.......... ខែ.............. ឆ្នាំ២០១៨ | |

**បញ្ជាក់៖** -ករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀត ដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។

-ពេលបង្ហាញខ្លួនសូមយកដីកានេះជូនក្រឡាបញ្ជីទទួលបន្ទុក។

-ជូនភ្ជាប់ជាមួយនឹងពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ (ថតចម្លង) [សម្រាប់ចុងចម្លើយ]

## ឧបសម្ព័ន្ធ
## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំធ្វើដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ឬ នៅទីណាមួយ តាមការព្រមព្រៀងរបស់គូក្តី ។ បើមិនមានការចុះសម្រុងគ្នាទេ តុលាការជាអ្នកសម្រេច ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មក ក្រឡាបញ្ជីត្រូវអានប្រារព្ធវាទ ខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថ ថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង ។

### ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និង បារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្វែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និង បានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះមកធ្វើជាសាក្សី ឱ្យឆ្លើយឱ្យ បានទៀងត្រង់ តាមពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និង បានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់

ប្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង ព្រោះជាញាតិ សាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និង បារមីដីសក្តិសិទ្ធិក្នុងលោក ជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់រាប់អាន លុះអនាគតជាតិ បានជួបតែ សេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តី បំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និង បានចាំផ្ទាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និង បារមីដីសក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និង ស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និង រស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំបញ្ចូលភស្តុតាង

ខ្ញុំបាទឈ្មោះ................................ ភេទ.............. ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវលេខ ............ សង្កាត់/ឃុំ ..................... ខណ្ឌ/ស្រុក ..................... រាជធានី/ខេត្ត....................................។

**សូមគោរពជូន**

**លោកចៅក្រមនៃសាលាដំបូងរាជធានី/ខេត្ត..............................**

*សូមទានជ្រាប*។

**កម្មវត្ថុ៖** សំណើសុំដាក់បញ្ចូលភស្តុតាងជាឯកសារទៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ..........ចុះថ្ងៃទី........ ខែ....... ឆ្នាំ..................... របស់សាលាដំបូង...............................................។

**យោង ៖** -សំណុំរឿងរដ្ឋប្បវេណីលេខៈ ............ ចុះថ្ងៃទី........... ខែ......... ឆ្នាំ.......... របស់សាលាដំបូងរាជធានី/ខេ

-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

-.....................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទមានកិត្តិយសសូមគោរពជូន **លោកចៅក្រម** មេត្តា ជ្រាបថា៖

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

.............................................................................................................................................

។អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកចៅក្រម** មេត្តសម្រេចទទួលនូវភស្តុតាងដូចដែល មាននៅក្នុងកម្មវត្ថុខាងលើដោយក្តីមេត្តាអនុគ្រោះបំផុត។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី........ ខែ......... ឆ្នាំ២០១៨

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត..........

លេខ....................បស

## ដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ

យើង ជាចៅក្រមសាលាដំបូងខេត្ត ទទួលបន្ទុកចាត់ការពាក្យបណ្តឹងអង្គសេចក្តី លេខ..........ចុះថ្ងៃទី........ខែ........ឆ្នាំ២០០...។

បានឃើញបទប្បញ្ញត្តិមាត្រា១៥២ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦។

បានឃើញពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសាររបស់ឈ្មោះ........................ជាភាគីដើមចោទ / ភាគីចុងចម្លើយ។

**យល់ឃើញថា:** ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសាររបស់ឈ្មោះ..................................មានមូលហេតុត្រឹមត្រូវ ។

### បង្គាប់ចត

ឈ្មោះ..............................ជាភាគីដើមចោទ/ចុងចម្លើយឱ្យក្នុងសំណុំរឿងនៃបណ្តឹងអង្គសេចក្តីលេខ.............ចុះថ្ងៃទី........ខែ..........ឆ្នាំ........ផ្តល់នូវឯកសារ :

១/

២/

៣/

មកឱ្យតុលាការខេត្ត ដើម្បីបានពិនិត្យតាមនីតិវិធីក្នុងអំឡុងពេល០៧ថ្ងៃគិតចាប់ពីថ្ងៃទី...........ដល់ថ្ងៃទី.......ខែ..........ឆ្នាំ.........។

ដីកាសម្រេចនេះឈ្មោះ..................................អាចប្តឹងជំទាស់បាន។

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

ចៅក្រម

បានទទួល

ថ្ងៃទី......ខែ..........ឆ្នាំ.២០០....

បុគ្គលត្រូវផ្តល់ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំថែរក្សាការពារភស្តុតាង

ខ្ញុំបាទឈ្មោះ.................................. ភេទ.............. ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.............. ផ្លូវលេខ ............ សង្កាត់/ឃុំ ..................... ខណ្ឌ/ស្រុក ..................... រាជធានី/ខេត្ត....................................។

## សូមគោរពជូន

## លោកចៅក្រមនៃសាលាដំបូងរាជធានី/ខេត្ត.............................

*សូមទានជ្រាប*។

**កម្មវត្ថុ៖** សំណើសុំឱ្យតុលាការធ្វើការថែរក្សាការពារនូវភស្តុតាងជាឯកសារស្តីពីកិច្ចសន្យាទិញ-លក់ រវាងឈ្មោះ........ និងឈ្មោះ............................

**យោង ៖** -ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦

-.......................................................................................................................

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំបាទមានកិត្តិយសសូមគោរពជូន**លោកចៅក្រម**មេត្តា ជ្រាបថា៖ដោយមូលថានាងខ្ញុំ/ខ្ញុំបាទ មានភាពលំបាកក្នុងការថែរក្សានិងការពារនូវភស្តុតាងដែលត្រៀមសម្រាប់ធ្វើ បណ្តឹងអង្គសេចក្តីនៅក្នុងនីតិវិធីរបស់តុលាការ និងការពារសន្តិសុខដល់រូបនាងខ្ញុំ/ខ្ញុំបាទផ្ទាល់ដូចនេះនាងខ្ញុំ/ខ្ញុំបាទ បានសម្រេចចិត្តសុំ ឱ្យតុលាការមេត្តា ថែរក្សាការពារនូវភស្តុតាងជាឯកសារមួយនេះ។ អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកចៅក្រម** មេត្តសម្រេចទទួលថែរក្សាការពារភស្តុតាងដូចដែលមាននៅ ក្នុងកម្មវត្ថុខាងលើដោយក្តីមេត្តាអនុគ្រោះបំផុត។

សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី........ ខែ......... ឆ្នាំ២០១៨

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត..........

៚៚៚❖៚៚៚

លេខ....................ចស

## ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង

---❖---

យើង ជាចៅក្រមសាលាដំបូងខេត្ត ទទួលបន្ទុកចាត់ការពាក្យសុំឱ្យថែរក្សាការពារភស្តុតាង លេខ............ចុះថ្ងៃទី........ខែ........ឆ្នាំ២០០...។

បានឃើញបទប្បញ្ញត្តិមាត្រា១៦៣.១៦៤.១៦៧ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦។

បានឃើញ....................................................................................................................................................

....................................................................................................................................................

....................................................................................................................................................

យល់ឃើញថាៈចាំបាច់ចេញដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាងដើម្បី...............................

.......... ....................................................................................................................................................

....................................................................................................................................................

ស ម្រេ ច

ចាត់វិធានការឱ្យថែរក្សាភស្តុតាងដោយ....................................................................................

....................................................................................................................................................

....................................................................................................................................................

អាស័យដ្ឋាន :....................................................................................................................................................

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

ចៅក្រម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត

លេខ....................បស

# ដីកាសម្រេចលើកចោលពាក្យសុំឱ្យថែរក្សាការពារភស្តុតាង

យើង ជាចៅក្រមសាលាដំបូងខេត្ត ទទួលបន្ទុកចាត់ការពាក្យសុំឱ្យថែរក្សាការពារភស្តុតាង លេខ............ចុះថ្ងៃទី........ខែ........ឆ្នាំ២០០...។

អ្នកសុំ :.......................................................,.......................................................

អាស័យដ្ឋាន:.......................................................................................................

បានឃើញបទប្បញ្ញត្តិមាត្រា១៦៣.១៦៤.១៦៥.១៦៨ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦។

ខ្លឹមសារដីកាសម្រេចដែលសុំឱ្យថែរក្សាការពារភស្តុតាង:..........................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

យល់ឃើញថា:ពាក្យសុំចេញដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០០...របស់ឈ្មោះ.......................ធ្វើឡើងមិនបានត្រឹមត្រូវតាមទម្រង់ពាក្យសុំដូចបញ្ញត្តក្នុងមាត្រា១៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី និង ពុំមានមូលហេតុ ពុំមានសំអាងហេតុត្រឹមត្រូវឡើយ។

## ស ម្រេ ច

លើកចោលនូវពាក្យសុំឱ្យថែរក្សាភស្តុតាង ចុះថ្ងៃទី......ខែ........ឆ្នាំ២០០..របស់ឈ្មោះ......................

ដីកាសម្រេចនេះអ្នកដាក់ពាក្យសុំឈ្មោះ..................................................អាចប្តឹងជំទាស់បាន។

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

ចៅក្រម

បានទទួល

ថ្ងៃទី......ខែ..........ឆ្នាំ.២០០....

បុគ្គលអ្នកសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្ត..........

លេខ....................បស

## ដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង

យើង ជាចៅក្រមសាលាដំបូងខេត្ត ទទួលបន្ទុកចាត់ការពាក្យសុំឱ្យថែរក្សាការពារភស្តុតាង លេខ............ចុះថ្ងៃទី........ខែ........ឆ្នាំ២០០...។

អ្នកសុំ :..........................................................................................

អាស័យដ្ឋាន:..........................................................................................

បានឃើញបទប្បញ្ញត្តិមាត្រា១៦៣.១៦៤.១៦៥ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦ ។

ខ្លឹមសារដីកាសម្រេចដែលសុំឱ្យថែរក្សាការពារភស្តុតាង:..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

**យល់ឃើញថា:**ពាក្យសុំចេញដីកាសម្រេចឱ្យថែរក្សាការពារភស្តុតាង ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០០... របស់ឈ្មោះ......................................ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ពាក្យសុំដូចបញ្ញត្តក្នុងមាត្រា១៦៥ ក្រមនីតិវិធីរដ្ឋប្បវេណី និងមានមូលហេតុ សំអាងហេតុត្រឹមត្រូវ ។

**ស ម្រ េ ច**

ចាត់វិធានការឱ្យថែរក្សាភស្តុតាងដោយ..........................................................................................

..........................................................................................

..........................................................................................

អាស័យដ្ឋាន :..........................................................................................

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

**ចៅក្រម**

បានទទួល

ថ្ងៃទី......ខែ..........ឆ្នាំ.២០០....

បុគ្គលអ្នកសុំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត..........

លេខ.....................ចស

## ដីកាសម្រេចបង្គាប់ឱ្យថែរក្សាការពារភស្តុតាង

យើង ជាចៅក្រមសាលាដំបូងខេត្ត ។

បានឃើញបទប្បញ្ញត្តិមាត្រា១៦៣ ១៦៤ ១៦៥ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ។

បានឃើញពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសាររបស់ឈ្មោះ.........................ជាភាគីដើមចោទ / ភាគីចុងចម្លើយ ។

យល់ឃើញថាៈ ពាក្យសុំដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសាររបស់ឈ្មោះ.....................................មានមូលហេតុត្រឹមត្រូវ ។

### បង្គាប់មក

ឈ្មោះ.................................ជាភាគីដើមចោទ/ចុងចម្លើយឱ្យក្នុងសំណុំរឿងនៃបណ្តឹងអង្គសេចក្តីលេខ ...........ចុះថ្ងៃទី.......ខែ.........ឆ្នាំ.........ផ្តល់នូវឯកសារ :

១/

២/

៣/

មកឱ្យតុលាការខេត្តបាត់ដំបងដើម្បីបានពិនិត្យតាមនីតិវិធី ក្នុងអំឡុងពេល០៧ថ្ងៃ គិតចាប់ពីថ្ងៃទី............ ដល់ថ្ងៃទី.......ខែ..........ឆ្នាំ.......... ។

ដីកាសម្រេចនេះឈ្មោះ.............................អាចប្តឹងជំទាស់បាន ។

ធ្វើនៅ . ថ្ងៃទី.........ខែ..........ឆ្នាំ២០០...

បានទទួល

ចៅក្រម

ថ្ងៃទី......ខែ..........ឆ្នាំ.២០០....

បុគ្គលត្រូវផ្តល់ឯកសារ